ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរអប់រំយុវជន និង កីឡាខេត្តបាត់ដំបង**

វិទ្យាល័យ ណេតយ៉ង់

## ស្នាដៃចូលរួមអបអរទិវាអំណានជាតិលើកទី៩

**ប្រធានបទ**

# “ តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ ការអប់រំសីលធម៌ និង ចរិយាធម៌ ”

បេក្ខជន **ខុត សុវ៉ាន់ដា** ភេទ ប្រុស កើតថ្ងៃទី០២ ខែឧសភា ឆ្នាំ ១៩៨៨

ជាគ្រូបង្រៀននៅវិទ្យាល័យ ណេតយ៉ង់ ខេត្តបាត់ដំបង

លេខទូរស័ព្ទ ៖ ០៩៥៤៣០៧៥១

ព.ស . ២៥៦៧ គ.ស. ២០២៤

# ប្រវត្តិរូបសង្ខេប

| | |
|---|---|
| ឈ្មោះ | ៖ វុត សុវ៉ាន់ដា |
| ភេទ | ៖ ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ៖ ០២ ឧសភា ១៩៨៨ |
| ទីកន្លែងកំណើត | ៖ ភូមិព្រៃកូនសេក ឃុំសាមគ្គី ស្រុកទីរួមខេត្ត ខេត្តបាត់ដំបង |
| មុខរបរ | ៖ គ្រូបង្រៀន |
| អង្គភាពបម្រើការងារ | ៖ វិទ្យាល័យនេតយ៉ង់ |
| លេខតេឡេក្រាម | ៖ 087507337 |
| ខេត្ត | ៖ បាត់ដំបង |

# មាតិកា

សេចក្ដីផ្ដើម
១.អំពីព្រះពុទ្ធសាសនា..........១
១.១. ពុទ្ធប្រវត្តិសង្ខេប..........១
១.២. វឌ្ឍនភាពនៃព្រះពុទ្ធសាសនា..........១
១.៣. វត្តមានព្រះពុទ្ធសាសនានៅកម្ពុជា..........៣
១.៤. គោលទស្សនៈសំខាន់ៗរបស់ព្រះពុទ្ធសាសនា ..........៥
ក. ទស្សនៈកម្មផល..........៥
ខ. លក្ខណៈនៃសភាវៈ ( ត្រៃលក្ខណ៍ )..........៦
គ. បញ្ហាសុខៈ..........៧
ឃ. សម្បត្តិបីប្រការ..........៧
ង. ចតុអរិយសច្ចៈ..........៧
២. តួនាទីព្រះពុទ្ធសាសនាក្នុងលើកកម្ពស់ការអប់រំសីលធម៌..........៧
២.១. និយមន័យសីលធម៌..........៨
ក. សីលធម៌ចំពោះខ្លួនឯង..........៨
ខ. សីលធម៌ចំពោះគ្រួសារ..........៨
គ. សីលធម៌ចំពោះវិជ្ជាជីវៈ..........៨
ឃ. សីលធម៌ចំពោះសង្គមជាតិ..........៩
ង. សីលធម៌ចំពោះសកលលោក..........៩
២.២. សីលធម៌ក្នុងមង្គលធម៌ទាំង៣៨ប្រការរបស់ព្រះពុទ្ធសាសនា..........៩
២.៣. ការអប់រំសីលធម៌នៃព្រះពុទ្ធសាសនា ..........១១
២.៤. ការប្រណិបត្តន៍នូវកុសលបថ ១០..........១១
២.៥. ការស្គាល់ពីតួនាទីរបស់ខ្លួន..........១១
ក. តួនាទីមាតាបិតា..........១២
ខ. តួនាទីបុត្រធីតា..........១២
គ. តួនាទីស្វាមី..........១២
ឃ. តួនាទីភរិយា..........១២
ង. តួនាទីគ្រូបាចារ្យ..........១២
ច. តួនាទីសិស្ស..........១៣
ឆ. តួនាទីចៅហ្វាយនាយ..........១៣
ជ.តួនាទីអ្នកបម្រើការងារ..........១៣
ឈ. តួនាទីមិត្ត..........១៣

៣. តួនាទីព្រះពុទ្ធសាសនាក្នុងការលើកម្ពស់ការអប់រំចរិយាធម៌..........................................................១៣
៣.១. និយមន័យចរិយាធម៌.................................................................................................១៣
៣.២.ការប្រណិបត្តន៍នូវចរិយាធម៌........................................................................................១៤
ក. ការលើកម្ពស់អប់រំសុជីវធម៌.................................................................................១៥
ខ. ការលើកកម្ពស់អប់រំគុណធម៌...............................................................................១៥
គ. ការលើកម្ពស់អប់រំព្រហ្មវិហារធម៌.........................................................................១៥
៤.មធ្យោបាយលើកម្ពស់ការអប់រំសីលធម៌ និង ចរិយធម៌...........................................................................១៧
៤.១. ការផ្សព្វផ្សាយធម្មទេសនាឬ ធម្មទាន.........................................................................១៧
៤.២. ការផ្សព្វផ្សាយតាមបណ្តាញសង្គម..............................................................................១៧
៤.៣. ការផ្សព្វផ្សាយតាមសកម្មភាពផ្សេងៗ..........................................................................១៧
៤.៤. ការផ្សព្វផ្សាយតាមអក្សរសិល្ប៍....................................................................................១៩

# តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់អប់រំសីលធម៌ និង ចរិយាធម៌

## សេចក្តីផ្តើម

ប្រជាជនខ្មែរជាជាតិសាសន៍មួយដែលមានខឿនវប្បធម៌ដ៏សម្បូរបែប ប្លែកៗ និងមានចំណាស់ភាពក្នុងដែនដីអាស៊ីមួយផងដែរ ។ វត្តមាននៃការកាត់ពូជពិសេសនៃអំបូរម៉ាឡេនេស៊ីយ៉ាងនិង ឥណ្ឌូនេស៊ីយ៉ាងនេះ បានកសាងនូវអរិយធម៌មួយប្រកបដោយគុណតម្លៃ យ៉ាងណាមិញ ជំនឿរបស់ប្រជាជនខ្មែរត្រូវបានគេប្រៀបទៅនឹងអត្តសញ្ញាណជាតិ ព្រលឹងជាតិមួយផងដែរ ដែលប្រជាជនខ្មែរពីមួយជំនាន់ទៅមួយជំនាន់បានប្រតិបត្តិនិងបន្សល់នូវមត៌កជាច្រើនសម្រាប់ប្រយោជន៍ជាតិទាំងមូល ។ ក្នុងនោះ ព្រះពុទ្ធសាសនា ជាសាសនាមួយដែលប្រជាជនខ្មែរគោរព និងឲ្យតម្លៃតាំងសម័យនគរភ្នំរហូតមកដល់ពេលបច្ចុប្បន្ននេះ យ៉ាងជាប់លាប់និង មុតមាំស្របនឹងការវិវត្តនៃស្ថានភាពសង្គម។

ពិតណាស់ ព្រះពុទ្ធសាសនាត្រូវបានប្រជាជនខ្មែរគោរពប្រណិបត្តន៍ជាង ៩៥%ទូទាំងប្រទេស ទើបរដ្ឋធម្មនុញ្ញចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ វត្ត ឬទីពុទ្ធបូជានានាត្រូវបានប្រជិដ្ឋានឡើងនៅរាយប៉ាយទូទាំងដែនដីកម្ពុជរដ្ឋដែលសបញ្ជាក់ថា ព្រះពុទ្ធសាសនានេះ មានភាពរីកចម្រើន និង ការគោរពប្រណិបត្តន៍យ៉ាងវិសេសរបស់ប្រជាជនខ្មែរពីមួយជំនាន់ទៅមួយជំនាន់ ក្នុងការញ៉ាំងនូវគោលលទ្ធិព្រះពុទ្ធសាសនាឲ្យជ្រួបជ្រាបក្នុងមនោគតិរបស់ប្រជាជនខ្មែរ ដុសខាត់ឲ្យកើតនូវមូលធនមនុស្ស សម្រាប់សង្គមជាតិទាំងមូល ។

ជាប្រត្យក្សនៃទស្សនាទាននេះ វត្តអារាម ត្រូវបានប្រជាជនខ្មែរ តាំងជាទីសក្ការផង ជាថ្នាលបណ្តុះចំណេះដឹងទាំងពុទ្ធចក្រ អាណាចក្រផង ទាំងជំនាញផង និង សីលធម៌ ចរិយាធម៌របស់កុលបុត្រខ្មែរតាំងពីសម័យកណ្តាលមក ដែលយើងអាចកំណត់បានថា វត្តអារាមព្រះពុទ្ធសាសនា មានតួនាទីសំខាន់ណាស់ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់បម្រើឲ្យប្រយោជន៍ជាតិ សាសនា ព្រះមហាក្សត្រ។

ក្នុងបរិបទសង្គមបច្ចុប្បន្ននេះ យើងមើលឃើញថាក្រមសីលធម៌ និងចរិយាធម៌ត្រូវបានធ្លាក់ចុះជាបណ្តើរ ទោះបីមានការយកចិត្តទុកដាក់ក្នុងការលើកស្ទួយវិស័យនេះពីស្ថាប័នពាក់ព័ន្ធនានាយ៉ាងណាក្តី ក្នុងនោះ យើងមើលឃើញថា ព្រះពុទ្ធសាសនា ជាលំហូរធំមួយដែលអាចញ៉ាំងឲ្យសីលធម៌ ចរិយាធម៌សង្គមបានប្រសើរឡើងវិញបាន ព្រោះព្រះពុទ្ធសាសនាត្រូវបានប្រជាជនខ្មែរមានជំនឿ និងគោរព ព្រមទាំងជាទស្សនវិជ្ជាអប់រំ និងជាសាសនាមនុស្សនិយមផងដែរ ។

ក្នុងលក្ខខ័ណ្ឌនេះ ភាពចាំបាច់នៃព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរបានផ្សារភ្ជាប់គ្នា ឬមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត ដែលបានកប់ក្នុងសណ្តានចិត្តប្រជាជនខ្មែរគ្រប់វ័យ ស្រទាប់វណ្ណៈ ហើយក្នុងនោះ ព្រះពុទ្ធសាសនា ត្រូវបានគេជឿថា ជាចលករសំខាន់បំផុតក្នុងការអបស្ទប អប់រំនូវគុណតម្លៃនៃសីលធម៌ ចរិយាធម៌សង្គមឲ្យមានភាពប្រសើរតាមរយៈរូបភាពផ្សេងៗ ។

# ១. អំពីព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសានា មកពីពាក្យថា ព្រះពុទ្ធ បូកផ្សំនឹងពាក្យសាសនា ។ ព្រះពុទ្ធ ជាបុគ្គលដែលសម្រេចបាននូវគុណជាតិនានា អ្នកដែលបានត្រាស់ដឹងនូវសព្វញ្ញុតាធម៌ទាំងឡាយ ។ ចំណែកពាក្យថា សាសនា មកពីបាលីថា សាសន ដែលមានន័យថា ការអប់រំទូន្មានប្រៀនប្រដៅ ។ ដូច្នេះ ព្រពុទ្ធសាសនាមានន័យថា ការអប់រំទូន្មានប្រៀបប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ជាគ្រូនៃយើង ។ សាសនាព្រះពុទ្ធ ជាសាសនាមួយដែលប្រជាជនខ្មែរនិយមគោរព តាំងពីបុរាណកាលមក រហូតដល់ពេលបច្ចុប្បន្ន ។ ព្រះពុទ្ធសាសនា ជាសាសនាផង ជាទស្សនវិជ្ជាផង ដែលបានដក់ជិតនៅក្នុងសន្តានចិត្តប្រជាជនខ្មែរពីមួយជំនាន់ទៅមួយជំនាន់ ហើតយបានចូលរួមយ៉ាងសកម្មសឹងគ្រប់វិស័យនៃសង្គមជាតិ។

## ១.១. ពុទ្ធប្រវត្តិសង្ខេប

ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម សិទ្ធត្ថ នាមត្រកូល គោតម ។ ជារាជបុត្រានៃព្រះបាទ សុទ្ធោទនៈ និង ព្រះនាងសិរីមហាមាយា ដែន កសៈ ប៉ែកខាងជើងប្រទេសឥណ្ឌា នាសតវត្សទី៦ មុនគ្រិស្តសករាជ ។ នាថ្ងៃព្រហស្បតិ៍ ១៥កើតពេញបូណ៌មី ខែអាសាធ ឆ្នាំរកា ទ្រង់បានចាប់បដិសន្ធិក្នុងផ្ទៃព្រះនាងសិរីមហាមាយា ប្រកបដោយហេតុភេទអស្ចារ្យផ្សេងៗ ។ លុះគម្រប់ទសមាស នាថ្ងៃ សុក្រ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំ ច ទ្រង់ប្រសូត្រ ក្រោមដើមសាលព្រឹក្សនាឧទ្យានលុម្ពនី ដែលព្រាហ្មណ៍ទាំងឡាយតាំងនាមថា សិទ្ធត្ថ ដែលព្រាហ្មណ៍ទាំងនេះបានទស្សន៍ទាយនូវលក្ខណៈរបស់រាជឱរសក្រកបដោយលក្ខណៈពីរយ៉ាងគឺអនាគតនឹងក្លាយជាស្តេចចក្រ ឬ ក្លាយជាព្រះពុទ្ធ ។ ការដែលទៅបួសស្វែងរកនូវសច្ចធម៌ដោយទតឃើញមនុស្សបួនប្រភេទមាន ចាស់ ឈឺ ស្លាប់ និងអ្នកបួស ទើបបិតាទ្រង់ការពារទ្រង់ដោយប្រការផ្សេងៗ។ ចំណែកព្រះមាតា ក្រោយប្រសូត្រ សិទ្ធត្ថបាន៧ថ្ងៃ ទ្រង់បានអស់ជន្មាយុ ភារៈដែលត្រូវរក្សារាជឱរសគឺ នាងបជាបតិគោតមី ជាម្តាយមីង។ ព្រះជន្មាយុបាន ១៦ ព្រះវស្សា ទ្រង់បានរៀបអភិសេកជាមួយព្រះនាង ពិម្ពាយសោធរា នាថ្ងៃសៅរ៍ ១៥កើតពេញបូណ៌មី ខែអាសាឍ ឆ្នាំ ឆ្លូវ ដែលទ្រង់មានជារាជបុត្រមួយអង្គនាម រាហុលកុមារ ។ ទ្រង់បានទតឃើញមនុស្ស៤ប្រភេទ និងសម្រេចព្រះទ័យទៅបួសនាថ្ងៃ ព្រហស្បតិ៍ ១៥កើតពេញបូណ៌មី ខែអាសាឍ ឆ្នាំថោះចំថ្ងៃដែលរាហុលកុមារប្រសូត្រ ។ ទ្រង់បានត្រាស់ដឹងនាថ្ងៃ ពុធ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្មាយុ ៣៥ព្រះវស្សា ដោយពេញនូវពុទ្ធកិច្ចទាំង៥រៀងរាល់ថ្ងៃ ។ ទ្រង់បានដាក់អាយុសង្ខារនៅថ្ងៃពុធ ១៥កើតពេញបូរណ៌ ខែមាឃឆ្នាំម្សាញ់និងបានចូលព្រះបរិនិព្វាននាថ្ងៃ អង្គារ ១៥កើតពេញបូណ៌មី ខែ ពិសាខ ឆ្នាំ ម្សាញ់ ។

## ១.២. វឌ្ឍនភាពនៃព្រះពុទ្ធសាសនា

ដោយឃើញថាមានភិក្ខុសង្ឃល្មមគ្រប់គ្រាប់ សម្រាប់ការផ្សព្វផ្សាយសច្ចធម៌ហើយ ព្រះសាស្តាបានត្រាស់ឲ្យសាវ័ករបស់ព្រះអង្គបំបែកគ្នាត្រាច់ទៅកាន់ចារិកផ្សេងៗ ដើម្បីសម្តែងនូវព្រះធម៌ប្រោសដល់ជនជាច្រើននាក់។ល។ ពេលនោះព្រះអង្គក៏ចេញដំណើរនិមន្តទៅកាន់ឧរុវេលាប្រទេស ក្នុងគោលបំណងដូចគ្នាដែរ ។

អស់រយៈពេល៤៥ព្រះវស្សា គត់បេសកកម្មនិងជាមហាករុណាគ្មានព្រំដែនរបស់ព្រះអង្គ ចំពោះមនុស្សជាតិទាំងមូល ព្រះបរមគ្រូបានលះបង់កម្លាំកាយចិត្តដោយមិនគិតអំពីខ្លួនព្រះអង្គឡើយក្នុងគោលបំណងផ្សព្វផ្សាយសច្ចធម៌និងមាគ៌ាឆ្ពោះទៅកាន់បរមសុខ ។ ព្រះចេស្តាបានយាងស្ទើរពេញផ្ទៃដីប្រទេសឥណ្ឌាភាគខាងជើង និងភាគខាង

កើត តាមរយៈវិរិយៈភាពរបស់ព្រះជិនស្រី និង សាវ័ករបស់ព្រះអង្គ ព្រះពុទ្ធសាសនាបានរីកចម្រើននិងចាក់ឫសយ៉ាងមាំនៅក្នុងប្រទេសឥណ្ឌានាសម័យកាលនោះ[1] ។

ចាប់តាំងពីផ្តើមកកើតឡើងដំបូងមកម្លេះ ព្រះពុទ្ធសាសនាមានលក្ខណៈជាសាសនទូត ហើយព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ជូនសមណទូត ដែលជាព្រះអរហន្ត៦១អង្គដំបូង រួមទាំងពុទ្ធអង្គផ្ទាល់ទៅកាន់ទិសផ្សេងៗ ដើម្បីផ្សព្វផ្សាយព្រះធម៌ ក្នុងគោលបំណងនៃសេចក្តីសុខចម្រើន និងជាប្រយោជន៍ដល់ជនច្រើន។ តាមរយៈការផ្សព្វផ្សាយសាសនទូតដោយមិនខ្លាចនឿយហត់នេះ ព្រះពុទ្ធសាសនាមានការរីកចម្រើន ទទួលការគោរពរាប់អាន ប្រតិបត្តិតាមដោយជនច្រើន ទាំងឋានៈទាបខ្ពស់ក្នុងមគ្គផលគ្រប់ៗគ្នា ។ ការផ្លាស់ប្តូរ និងទទួលយកដ៏អស្ចារ្យក្នុងប្រវត្តិសាស្ត្រនោះ គឺការផ្លាស់ប្តូរនិងទទួលយកព្រះពុទ្ធសាសនារបស់ស្តេចចក្រ មួយអង្គគឺ ព្រះបាទធម្មាសោក ដែលគ្រោងរាជ្យពីឆ្នាំ ២១៨ត្រូវនឹងឆ្នាំ ២៦៩ មុនគ.ស ។ ក្រោយពីការធ្វើសង្គ្រាមបង្ហូរឈាមក្នុងការវាទទីអំណាចរបស់ព្រះអង្គ ព្រះរាជាអង្គនេះមានការស្អប់ខ្ពើមនិងរន្ធត់ចំពោះសង្គ្រាមណាស់ ។ ទីបំផុត ព្រះអង្គបានស្គាល់សន្តិភាពពិត តាមរយៈការគោរពគោលការណ៍ព្រះពុទ្ធសាសនា ។ ព្រះអង្គបានក្លាយជាព្រះពុទ្ធសាសនូបត្ថម្ភដ៏ឆ្នើម ហើយព្រះអង្គបានគ្រប់គ្រងដោយធម៌ គោរពគោលការណ៍សន្តិភាព បានយកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ពេលនោះហើយដែលប្រទេសឥណ្ឌាទាំងមូលស្គាល់ពាក្យថារួបរួម ផ្សះផ្សា សាមគ្គី រីកចម្រើន និងពោរពេញដោយសេចក្តីសុខស្ងប់ វិបុលសុខ សន្តិភាពនិងវឌ្ឍនភាព។ល។

នៅក្នុងរាជរបស់ព្រះបាទធម្មាសោកនោះ ព្រះអង្គបានបញ្ជូនសមណទូតនៅកាន់តំបន់ផ្សេងៗ ដើម្បីផ្សព្វផ្សាយព្រះធម៌របស់ព្រះចេស្តា ។ តាមឯកសារជាច្រើនបានអះអាងថា ព្រះអង្គមិនត្រឹមតែបញ្ជូនទៅកាន់ទីជិតនៃប្រទេសឥណ្ឌាប៉ុណ្ណោះទេ ប៉ុន្តែទៅកាន់តែឆ្ងាយ ដូចជានៅប្រទេស អេស៊ីប អាហ្វ្រិកខាងជើង ស៊ីរីយ៉ា និងម៉ាសេដូនី ជាដើម ។ សមណទូតទាំងអស់នោះ បានទៅផ្សព្វផ្សាយព្រះធម៌ ដែលយើងស្គាល់ថាព្រះពុទ្ធសាសនាថេរវាទសព្វថ្ងៃដូចដែលយើងគោរពរាប់អាននៅប្រទេសស្រីលង្កា ភូមា ថៃឡង់ដ៏ លាវ និងកម្ពុជា ។

ដោយពេលវេលាកន្លងទៅ ព្រះពុទ្ធសាសនាបានវិវត្តន៍ទៅរកទម្រង់សេរីមួយដែលយើងស្គាល់ថាព្រះពុទ្ធសាសនាមហាយាន ។ ការចាប់ផ្តើមកើតឡើងនិកាយនេះ យើងគប្បីសិក្សានឹងត្រឡប់មើលព្រឹត្តិការណ៍សម័យកាលសង្គាយនាលើកទីពីរ ក្នុងឆ្នាំ ទី១០០ និងទីបី ក្នុងឆ្នាំ ២៣៤ ក្រោយពុទ្ធបរិនិព្វានមកវិញ ។ ព្រះពុទ្ធសាសនានិកាយមហាយាននេះមានការរីកចម្រើននៅសតវត្សទី១នៃគ្រិស្តសករាជដោយរីកផ្សាយទៅទិសខាងជើង មានប្រទេសចិន កូរ៉េ និងជប៉ុនជាទីកន្លែងដែលនិកាយនេះ ចាក់ឫសយ៉ាងរឹងមាំបំផុត រហូតមកដល់សព្វថ្ងៃនេះ ។

សេចក្តីបន្ថែម ទាក់ទងនឹងការផ្សព្វផ្សាយព្រះពុទ្ធសាសនារបស់ព្រះបាទធម្មាសោកទៅកាន់តំបន់ធំៗទាំង ៩ កន្លែងនោះ ខ្ញុំសូមដកស្រង់តែឈ្មោះទីកន្លែង និងសមណទូតទាំង៩ ក្រុមដូចមានរាយឈ្មោះនៅខាងក្រោមនេះគឺ ៖

១. ព្រះមជ្ឈន្តិកត្ថេរ ទៅកាស្មៀរ គន្ធារៈ ( បាគីស្ថាននិងអាហ្គានីស្ថាន )

២. ព្រះមហាទេវត្ថេរ ទៅមហិសមណ្ឌល ខេត្តម៉ៃស័រ ( Mysore )

---

[1] ភិក្ខុ ស៊ិន គង់ **ស្វែងយល់ពីព្រះពុទ្ធសាសនា** បោះពុម្ពឆ្នាំ ២០១១ ទំព័រ ១៣

៣. ព្រះរក្ខិតត្ថេរ ទៅវនវសីបរទេស ខាងឧត្តរទិសនៃខេត្តកន្នរៈ ( Kannara )

៤. ព្រះយោនកធម្មរក្ខិតត្ថេរ ទៅអបរន្តបទេស ខេត្តគុជរាត ( Gujrat )

៥. ព្រះមហាធំរក្ខិតត្ថេរ ទៅខេត្តមហារដ្ឋ ( Maharashtra ) ក្រុងមុំបាយបច្ចុប្បន្ន

៦. ព្រះមហារក្ខិតត្ថេរ ទៅយោនកប្បទេស ( អាណាក្រិក និងប្រទេសខ្លះក្នុងមជ្ឈិមបូព៌ា )

៧. ព្រះមជ្ឈិមត្ថេរទៅហិមវន្តប្បទេស តំបន់ហិមាល័យខាងឧត្តរទិស ( សន្និដ្ឋានថា ទីបេត៍ បូតាននិងម៉ុងហ្គោលបច្ចុប្បន្ន )

៨. ព្រះមហាមហិន្ទត្ថេរ ទៅតាម្ពបណ្ណិទ្វីប ( ដែនកោះស្រីលង្កា )

៩. ព្រះសោណត្ថេរ និង ឧត្តរត្ថេរ ទៅដែនដីសុវណ្ណភូមិ ( អាស៊ីអាគ្នេយ៍ )[2] ។

## ១.៣.វត្តមានព្រះពុទ្ធសាសនានៅកម្ពុជា

ព្រះពុទ្ធសាសនា ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក្រោមការគ្រប់គ្រងរបស់ព្រះបាទធម្មាសោក ដោយទ្រង់បានបញ្ជូនសមណទូតជាច្រើនចុះចាកមកផ្សព្វផ្សាយតាមទិសតំបន់នានាតាមតួនាទីរៀងៗខ្លួន ។ យ៉ាងណាមិញ នៅសតវត្សទី ៣មុនគ្រិស្តសរាជ ទ្រង់បានបញ្ជូនសមទូតពីរអង្គមកផ្សព្វផ្សាយនៅដែនដីសុវណ្ណភូមិ ។

សុវណ្ណភូមិជាឧបទ្វីស្ថិតនៅទ្វីបអាស៊ីអាគ្នេយ៍ ដែលក្នុងសតវត្សរ៍ទី៣នៃពុទ្ធសករាជមានប្រជាជាតិតែបីគឺភាគខាងលិចមានប្រជាជាតិមន ភាគកណ្តាលមានប្រជាជាតិខ្មែរ ភាគខាងកើតមានប្រជាជាតិចាម ។ ក្រោយមកសុវណ្ណភូមិមានឈ្មោះថា ឥណ្ឌូចិន ព្រោះនៅចន្លោះប្រទេសឥណ្ឌា និង ចិន បានដល់ប្រទេសភូមា ជ្រោយម៉ាលក្កា សៀម ខ្មែរ កូសាំងស៊ីន អណ្ណាម តុងកឹង [3]។

នៅក្នុងសម័យណាចក្រភ្នំ មនុស្សកាន់សាសនាធំៗទាំងពីររបស់ឥណ្ឌាគឺ ព្រាហ្មណ៍សាសនា និង ពុទ្ធសាសនា ។ក្នុងនោះវត្ថុបុរាណផ្សេងៗដែលទាក់ទងនឹងព្រះពុទ្ធសាសនាហើយដែលគេរកឃើញនៅតំបន់ផ្សេងៗនៅអាស៊ីអាគ្នេយ៍មានអាយុនៅសតវត្សរ៍ទី៣ នៃគ.ស ប៉ុណ្ណោះ ភស្តុតាងជាក់ស្តែង មានសិលាចារឹករ៉ូកាញ់ និង សិលាចារឹកតាព្រហ្មបាទីអាចបញ្ជាក់ពីលក្ខណៈនេះបាន ។

ព្រះពុទ្ធសាសនាមានភាពរុងរឿងជាពិសេសនៅសតវត្សរ៍ទី ៥ - ៦ ក្នុងរាជកាលព្រះបាទកៅណ្ឌិន្យជយវរ្ម័ន និងរុទ្រវរ្ម័នដោយមានការបញ្ជូនព្រះសង្ឃខ្មែរនិងជាតិឥណ្ឌាទៅកាន់ប្រទេសចិន ដើម្បីយកឯកសារផ្សេងៗ និងព្រះពុទ្ធរូបទៅថ្វាយស្តេចក្រុងចិន ឬជួយប្រែគម្ពីរពីសំស្ក្រឹតទៅចិនទៀតផង ។ ព្រះសង្ឃ សង្ឃបាល បានគង់នៅប្រទេសចិនរហូតដល់១៦ឆ្នាំ ហើយបានធ្វើការរហូត៥ការិយាល័យ ។ ព្រះចៅក្រុងចិនការស្ងើចយ៉ាងខ្លាំងចំពោះព្រះអង្គហើយចាត់ទុកជាព្រះគ្រូទៀតផង ។

---

[2] ភិក្ខុ ស៊ិន គង់ **ស្វែងយល់ពីព្រះពុទ្ធសាសនា** បោះពុម្ពឆ្នាំ ២០១១ ទំព័រ ៨៦

[3] ឥន្ទ ឱមសាម៉េង **ប្រវត្តិទស្សនៈសាសនាសីលធម៌ នយោបាយ** បោះពុម្ពឆ្នាំ ២០០៥ ទំព័រទី២០១

ក្នុងសម័យចេនឡា ព្រះពុទ្ធសាសនាមិនបាត់បង់ទេ តែទំនងជាត្រូវសាបសូន្យបន្តិចម្តងៗជាពិសេសនៅសតវត្សទី៧បើគេផ្អែកទៅលើសក្ខីភាព របស់ពុទ្ធសាសនិកចិនឈ្មោះ យី ស៊ីង ។ គេឃើញមានសិលាចារឹកមួយគត់និយាយពីភិក្ខុពីរអង្គ ។ ព្រះពុទ្ធសាសនាមហាយានឃើញមានគេគោរពបូជាបណ្តើរៗហើយ ។

ក្នុងសម័យអង្គរ ព្រះពុទ្ធសាសនាមហាយាន ហាក់មានភាពរីកចម្រើនខ្លាំងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ តែក្រោយមកព្រះបាទជ័យវរ្ម័នទី៨ បានផ្លាស់ប្តូរសាសនាមកសាសនាព្រាហ្មណ៍វិញ នាំឲ្យមានប្រតិកម្មយ៉ាងខ្លាំងភ្លាពីពួកព្រាហ្មណ៍ប្រឆាំងនឹងពុទ្ធសាសនារហូតដល់ការវាយកំទេចឬកោលលប់ព្រះពុទ្ធបដិមាចោល ។ ស្ថានការណ៍បែបនេះទំនងជាមានសភាពរ៉ាំរ៉ៃរហូតដល់មានបដិវត្តន៍នាយត្រសក់ផ្អែមដែលបានយកពុទ្ធសាសនាហិនយានមកជំនួសជាស្ថាពររហូតមកដល់សព្វថ្ងៃនេះ [4] ។

នៅក្នុងសម័យកណ្តាល ព្រះពុទ្ធសាសនាហីនយានបានចាក់ឫសយ៉ាងជ្រៅចូលក្នុងសង្គមខ្មែរ ជនជាតិខ្មែរគ្រប់ស្រទាប់វណ្ណៈចាប់តាំងពីព្រះមហាក្សត្រដល់ប្រជារាស្ត្រតូចតាចបំផុត សុទ្ធតែមានជំនឿមុតមាំលើព្រះពុទ្ធសាសនាដែលគេបានចាត់ទុកជាទីពឹងទីរលឹក ។ ចំនួនព្រះសង្ឃ និង វត្តអារាមកើនឡើងជាលំដាប់ ហើយមានមុខងារយ៉ាងសំខាន់ក្នុងវិស័យសង្គមកិច្ច និង អប់រំ ។

សម័យអាណានិគមនិយមបារាំងគិតចាប់ពីឆ្នាំ១៨៦៣ នៅពេលដែលព្រះនរោត្តមទ្រង់បានចុះសន្ធិសញ្ញាជាមួយបារាំងថ្ងៃ១១ខែសីហា ឆ្នាំ១៩៦៣នេះតែម្តង ក្នុងបំណងយកបារាំងជាខែលការពារប្រទេសកម្ពុជាពីការឈ្លានពានរបស់ ប្រទេសជិតខាងមានយួន សៀមជាដើម។ក្នុងកំឡុងសតវត្សទី ១៧, ១៨, ១៩ប្រទេសសៀមបានមានឥទ្ធិពលយ៉ាងខ្លាំងមកលើនយោបាយក្នុងស្រុករបស់ ខ្មែរ ដែលជាហេតុធ្វើឱ្យឥទ្ធិពលនៃប្រពៃណីសាសនាក៏លាយឡំជាមួយគ្នានោះ ផងដែរ។ ដូចជានៅក្នុងឆ្នាំ១៨៥៥ ព្រះបាទនរោត្តមបាននិមិន្តព្រះសង្ឃធម្មយុត្តិកនិកាយពីប្រទេសសៀម ចូលមកក្នុងស្រុកខ្មែរ ដើម្បីបង្កើតនិកាយនេះនៅក្នុងស្រុកខ្មែរផងដែរ។ សម្តេចប៉ានទ្រង់ជាព្រះសង្ឃខ្មែរក៏ប៉ុន្តែទ្រង់បានទៅសិក្សាប្រទេស សៀម ហើយត្រូវបានតែងតាំងជាព្រះសង្ឃធម្មយុត្តិដំបូងគេបង្អស់នៅក្នុង ប្រទេសកម្ពុជា គង់នៅក្នុងវត្តបទុមវត្តីក្រុងភ្នំពេញ។ ហើយប្រពៃណីនេះបានបន្តជាប់គ្រប់រាជការព្រះមហាក្សត្រខ្មែររហូតដល់ សព្វថ្ងៃ។ក្នុងសម័យអាណានិគមនេះ ក៏មិនខុសពីសម័យកណ្តាលប៉ុន្មានដែរ ព្រះពុទ្ធ សាសនាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមខ្មែរ ទាំងវិស័យសង្គមកិច្ច សុខាភិបាល អប់រំ យុត្តិធម៌ និងជាឃ្លាំងអភិរក្សអក្សរសាស្ត្រជាតិខ្មែរ ព្រមទាំងវប្បធម៌ប្រពៃណីរបស់ខ្មែរយើងផងដែរ។ ក្រោមការជិះជាន់របស់បារាំងមកលើប្រជាពលរដ្ឋខ្មែរ និងពុទ្ធសាសនា បានធ្វើឱ្យព្រះសង្ឃខ្មែរងើបឡើងតស៊ូបះបោរប្រឆាំងជាមួយបារាំង ប៉ុន្តែត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ រហូតដល់មានការចាប់ខ្លួនធ្វើទោសទណ្ឌទៀតផង។ តែទោះបីជាយ៉ាងណាក៏ដោយក៏ពុទ្ធសាសនានៅតែពង្រឹងខ្លួនជានិច្ចពុំមាន ការចុះញ៉មជាមួយពួកបារាំងនោះឡើយដែលនៅឆ្នាំ១៩១៤គេឃើញ មានការសាងសង់សាលាភាសាបាលីជាន់ខ្ពស់មួយនៅភ្នំពេញនិងក្រោយមកកែប្រែ ទៅជាមហាវិទ្យាល័យ ។ ការសិក្សាអប់រំចំពោះព្រះសង្ឃមិនត្រឹមតែចំណេះដឹងខាងភាសាបាលីប៉ុណ្ណោះ ទេ ក៏ប៉ុន្តែមូលដ្ឋានគ្រឹះនៃចំណេះដឹងទូទៅតាមបែបទំនើបក៏ត្រូវយកមក សិក្សារៀនសូត្រនៅឯសាលា

[4] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ភាគ១ភាគ២ បោះពុម្ពឆ្នាំ ១៩៧៣ ទំព័រទី១១៤

រៀនផងដែរ។ សាលា បាលីជាន់ទាបត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៣៣ដើម្បីផ្តល់លទ្ធភាព ឱ្យព្រះសង្ឃដែលទើបបួសថ្មីអាចសិក្សាពីភាសាបាលីនេះពីកម្រិតដំបូង បាន។

ពុទ្ធសាសនាសម័យខ្មែរក្រហម កំឡុងឆ្នាំ១៩៧៥នៅពេលដែលពួកខ្មែរក្រហមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញជាស្ថាពរ ពួកគេបានបំបាត់ ចោលទាំងអស់នូវជំនឿសាសនាផ្សេងៗ មិនឱ្យមានការគោរពប្រតិបត្តិអ្វីទាំងអស់ សូម្បីតែព្រះសង្ឃជាទីសក្ការៈត្រូវបានពួកនោះចាប់ផ្សឹកទាំងអស់។ ទីអារាមបានក្លាយទៅជាឃ្លាំងផ្ទុកនូវសម្ភារ សព្វាវុធ និងជាឃ្លាំងស្រូវ ឬត្រូវបំផ្លាញ ចោល។ តាមការប៉ាន់ស្មាននៅមុនរបបខ្មែរក្រហមព្រះសង្ឃខ្មែរមានចំនួនសរុប ចន្លោះពី ៦៥០០០អង្គ ទៅ៨០០០០ អង្គ។ ប៉ុន្តែក្រោយពេលដែលខ្មែរក្រហមបានត្រូវបានកម្ចាត់ នៅកំឡុងឆ្នាំ១៩៨០ព្រះសង្ឃត្រូវបានគេប្រមូលផ្តុំឡើងវិញសល់មិន ដល់៣០០០អង្គផង។

ពុទ្ធសាសនាសម័យក្រោយរបបប៉ុលពតក្រោយជ័យជំនះលើកងទ័ពខ្មែរក្រហមនៅឆ្នាំ១៩៧៩ ជំនឿសាសនាត្រូវបានបើកចំហឡើងវិញសម្រាប់ប្រជាពលរដ្ឋខ្មែរ។ ព្រះពុទ្ធសាសនា ក៏ត្រូវបានលើកតម្កើងសារជាថ្មីផងដែរ ដោយរដ្ឋាភិបាលបាននិមន្តព្រះសង្ឃខ្មែរ ដែលបានភៀសខ្លួនទៅប្រទេសវៀតណាមកាលពីកំឡុងសម័យខ្មែរក្រហមនោះ ចូលមកក្នុងប្រទេសកម្ពុជាវិញដើម្បីដឹកនាំព្រះពុទ្ធសាសនាឡើងវិញ។ នៅឆ្នាំ១៩៨១ព្រះសង្ឃខ្មែរមួយអង្គត្រូវបានតែងតាំងជាព្រះសង្ឃទី១នៃ កម្ពុជាគណៈមហានិកាយ ទ្រង់ព្រះនាមទេពវង្ស។ បច្ចុប្បន្ននេះព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ ប្រទេស ពុទ្ធសាសនាបានក្លាយជាអ្នកអប់រំដល់ពលរដ្ឋខ្មែរទូទៅពុទ្ធសាសនាក៏បានជួយសង្គមខ្មែរក្នុងវិស័យផ្សេងៗផងដែរ។ ព្រះសង្ឃមានរាប់សែនអង្គនៅទូទាំងប្រទេស ដែលទន្ទឹមនឹងនោះវត្តអារាមក៏ត្រូវបានកសាងឡើងជាបន្តបន្ទាប់ពាសពេញ ប្រទេសផងដែរ។ នៅឆ្នាំ១៩៩១ក្រោយពីធ្វើមាតុភូមិនិវត្តន៍ចូលកម្ពុជាវិញព្រះបាទ**នរោត្តម សីហនុ**បានរៀបចំឡើងវិញនូវរចនាសម្ព័ន្ធដឹកនាំពុទ្ធសាសនាដោយមានទាំង ធម្មយុត្តិកនិកាយ និងមហានិកាយ។ទន្ទឹមនឹងការចាត់ទុកព្រះ ពុទ្ធសាសនាជាសាសនារបស់រដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជានៅឆ្នាំ ១៩៩១ ការប្រកាន់ជំនឿសាសនាដទៃទៀតក៏ត្រូវបានគាំទ្រពីរដ្ឋាភិបាលផងដែរ។

ក្រោមកិច្ចដឹកនាំនៃបិតាសន្តិភាពសម្តេច តេជោ **ហ៊ុន សែន** នៃនយោបាយ**ឈ្នះ ឈ្នះ** បាបបង្រួបបង្រួមជាតិឲ្យមានពន្លឺសន្តិភាពពេញលេញ ប្រជាជនមានជំនឿ និងគោរពប្រណិតបត្តន៍សាសនារបស់ខ្លួនដោយស្មើរភាពនិងភាតរភាព ដែលវត្តអារាមត្រូវបានកសាងជាបន្តបន្ទាប់ ក្រោមកិច្ចឧបត្ថម្ភដ៏ជ្រះថ្លារបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ព្រមទាំងសប្បុរសជននានាទាំងក្នុង និងក្រៅប្រទេស នាំឲ្យព្រះពុទ្ធសាសនានៅជាម្លប់ ក្នុងការអប់រំទូន្មាន ជាពិសេសផ្នែកសីលធម៌ និង ចរិយាធម៌ ក្នុងសង្គម ។

## ១.៤. គោលទស្សនៈសំខាន់ៗនៃព្រះពុទ្ធសាសនា

### *ក. ទស្សនៈកម្មផល*

ទស្សនៈកម្មផលរបស់ព្រះពុទ្ធបរមគ្រូនៃយើង មានទំនាក់ទំនងទៅនឹងការវិលកើត ស្លាប់នៃសត្វ លោក ។ នៅក្នុងព្រាហ្មណ៍លទ្ធិ ភាវៈកើតឡើងដោយមានអាទិទេពជាអ្នកបង្កើត ។ ចំណែកក្នុងពុទ្ធលទ្ធិ ភាវៈកើតឡើងដោយខ្លួនឯងតាមច្បាប់ធម្មជាតិ ។ មនុស្ស ឬសត្វធាតុដែលកើត ឬស្លាប់គឺដោយសារខន្ធទាំង ៥ (រូបក្ខន្ធ-វេទនាក្ខន-សញ្ញាក្ខន្ធ-សង្ខារក្ខន្ធ-វិញ្ញាណក្ខន្ធ ) បានជួបប៉ះទង្គិចគ្នាផ្តុំផ្សំគ្នាហើយកើតឡើង ។ ភាវៈដែលមានកំណើត ហើយបែបនេះរមែងមានការ ប្រែប្រួលជំ ជាត់ ហើយទ្រុឌទ្រោមរួចរលត់ខន្ធទាំង ៥ ទៅវិញ ( ស្លាប់ ) រួចហើយទើបមានការប៉ះទង្គិចផ្តុំផ្សំគ្នាឡើងវិញជាថ្មីទៀត( ជីវិតថ្មី ) យ៉ាងនេះរៀងដរាបទៅ ។

ក្នុងទស្សនៈនេះគេចាត់ទុកការស្លាប់ជាខណៈមួយ ដែលខន្ធទាំងប្រាំត្រូវរលាយ ហើយចាត់ទុកការកើតជាខណៈមួយដែលខន្ធទាំង ៥ ផ្គុំផ្សំជាថ្មីឡើងវិញ ។ ខន្ធទាំង ៥ នៃមនុស្សសត្វត្រូវរលាយរលត់ ទៅវិញនៅពេលស្លាប់ក៏ពិតមែនហើយប៉ុន្តែនៅ សល់ថាមពល ឬចំហាយនៃខន្ធ ដែលបានប៉ះទង្គិចនូវធាតុឯទៀតៗ បណ្តាលឲ្យកើតមានជារូបមួយឡើងទៀត ។ ថាមពលឬចំហាយ នៃជីវិតចាស់នេះមានឈ្មោះថា "កម្មផល" នេះឯង ។ ដូចនេះជីវិតចាស់មានទំនាក់ទំនងជាមួយជីវិតថ្មី ។ ជីវិតចាស់ និងជីវិតថ្មីដូចគ្នាផងប្លែកគ្នាផង ។ ដូចគ្នាត្រង់ជីវិតថ្មីទទួលចំហាយកម្មផលពីជីវិតចាស់ ប៉ុន្តែពុំដូច ឬ ប្លែកគ្នាត្រង់ជីវិតថ្មីមានការកសាងការអប់រំថ្មីៗទៀត ។

ទស្សនៈពុទ្ធនិយមបានពន្យល់ឃើញថា សត្វលោកទាំងឡាយរមែងវិលកើតវិលស្លាប់មិនចេះអស់មិនចេះហើយក្នុងសំសារៈ ។ កាលបើកើតឡើងហើយរមែងមានចាស់ឈឺ ស្លាប់ ហើយនៅ ពេលចាស់រមែងជួបប្រទះ នឹងទុក្ខសោកពេគាព្យាធិ និងសេចក្តីលំបាកវេទនាផ្សេងៗមិន អាចជៀសផុត។ ឯការដែលនាំឲ្យផុតចាកជរា ឈឺ ស្លាប់និងទុក្ខសោកផ្សេងៗបានគឺមិន ចាប់កំណើត តទៅទៀត ព្រះពុទ្ធសាសនាឲ្យឈ្មោះថា "និព្វាន" ។

ពាក្យថាកម្ម មានន័យថា អំពើ ការងារ កិច្ចការឬ ទង្វើ ដែលមនុស្សម្នាក់ៗបានប្រព្រឹត្តិដោយកាយក្តី-ចិត្តក្តី ។ កម្មដែលសំខាន់ចែកចេញជាបីយ៉ាង :

– កុសលកម្ម : គឺអំពើជាកុសល(អំពើល្អ)
– អកុសលកម្ម : គឺអំពើជាអកុសល(អំពើអាក្រក់)
– អព្យាកតកម្ម : គឺអំពើជាអព្យាក្រឹត (មិនល្អមិនអាក្រក់) [5]។

ឯពាក្យថាផល គឺផ្លែផ្កាដែលលេចចេញអំពីកម្ម ។ បើកម្មល្អ ផលល្អ បើកម្មអាក្រក់ ផលអាក្រក់ ។ មនុស្សជាអ្នកកសាងកម្មខ្លួនឯង ហើយត្រូវទទួលយកផលនៃកម្មនេះខ្លួនឯងដែរ ។ ដូចនេះតាមទស្សនៈពុទ្ធនិយម មនុស្សដែលមានលក្ខណៈល្អ អាក្រក់ ល្ងង់ ឆ្លាត មាន ក្រ ស ខ្មៅ ។ល។ គឺមកពីការកសាង ឬអំពើរបស់មនុស្សម្នាក់ៗនេះឯង ។ម្យ៉ាងទៀតអំពើល្អ និងអំពើអាក្រក់ពុំលុប លាងឬសងគ្នាបានទេ។អំពើល្អរមែងផលិតផលល្អ អំពើអាក្រក់រមែងផលិតផលអាក្រក់។ ប្រសិន បើអំពើនោះល្អផងអាក្រក់ផង លទ្ធផលក៏ល្អផងអាក្រក់ផងដែរ ។ ឯផលកម្មមិនសាបសូន្យទេគ្រាន់តែទទួលយូរឬឆាប់ប៉ុណ្ណោះ  កម្មខ្លះផ្តល់ផលភ្លាមៗ ក្នុងបច្ចុប្បន្នជាតិ  កម្មខ្លះផ្តល់ផលក្នុងជាតិខាងមុខ  កម្មខ្លះទៀតផ្តល់ផលក្នុងជាតិជាលំដាប់តៗទៅទៀត ។

ក្នុងន័យនេះ យើងគ្រប់គ្នាត្រូវប្រកាន់ភ្ជាប់នូវកុសលកម្ម និងវៀរចាកនូវអកុសលកម្មនានា ស្របនឹងពុទ្ធភាសិតចែងថា " ***អ្នកណាសាបព្រួសពូជបែបណា អ្នកនោះនឹងបានផលបែបនោះ*** "  ឬ " ***សាងបុណ្យបានបុណ្យ សាងបាបបានបាប*** " ។ ដូច្នេះការសាងអំពើកុលល ឬកុសលបទ១០ជាកិច្ចត្រូវបំពេញ និងវៀរចាកនូវអកុសលបទ១០ ។

***ខ. លក្ខណៈនៃសភាវៈ ( ត្រៃលក្ខណ៍ )***

លក្ខណៈសកលបីយ៉ាងនៃជីវិតគឺ

- អនិច្ចំ ៖ ភាវៈទាំងអស់សុទ្ធតែមិនទៀងទាត់  ក្នុងការកើតស្លាប់ចម្រើនវិនាស មិនទៀតទាត់ ។
- ទុក្ខំ ៖  ភាវៈទាំងអស់ឲ្យតែមាននាម និងរូប សុទ្ធតែមានទុក្ខដូចគ្នា ។
- អនត្តា ៖ ភាវៈទាំងអស់សុទ្ធតែមិនមែនជារបស់ខ្លួន ។

សរុបមក ភាវៈទាំងពួងក្នុងធម្មជាតិត្រូវតែមានការប្រែប្រួលដោយភ្ជាប់ហេតុនិងផល ។

[5] គេហទំព័រ ហ្វេសប៊ុក ព្រះភិក្ខុ Ean Phearort

*គ. បញ្ញាសុខៈ*

ដើម្បីបានសុខគឺលះបង់តណ្ហា និង កំចាត់អវិជ្ជា មិនមែនប្រមាថ ធ្វេសប្រហែស តម្កល់ចិត្តក្នុងសីល សមាធិ បញ្ញា និងលះបង់អត្តៈ ( កុំប្រកាន់ថាខ្លួន ជារបស់ខ្លួន)

*ឃ.សម្បត្តិ៣ប្រការ*

- សម្បត្តិមនុស្ស ឬ មនុស្សសម្បត្តិ គឺសម្បត្តិដែលើប្រសើរជាងសត្វតិរច្ឆាន ។
- សម្បត្តិសួគ៌ ឬ សគ្គសម្បត្តិ គឺសម្បត្តិដែលកើតឡើងដោយចំណងនិស្ស័យនៃបុញ្ញកម្ម ។
- សម្បត្តិនិព្វាន ឬ និព្វានសម្បត្តិ គឺសម្បត្តិខ្ពស់បំផុតឥតមានភ័យណាមួយក្នុងលោកចូលមកបៀតបៀនបានឡើយ ។

*ង. ចតុអរិយសច្ចៈ*

- ទុក្ខអរិយសច្ចៈ ៖ទុកដែលកើតសភាពពិតមាន ជាតិទុក្ខ គឺទុក្ខព្រោះមានកំណើត ។ ជរាទុក្ខ គឺទុក្ខព្រោះវ័យចាស់ ។ ព្យាធិទុក្ខ គឺទុក្ខព្រោះមានជំងឺ ឈឺ ។ មរណទុក្ខ គឺទុក្ខព្រោះស្លាប់ ។
- សមុទយអរិយសច្ចៈ ៖ ហេតុដែលនាំឲ្យកើតទុក្ខព្រោះតែអវិជ្ជា និង តណ្ហា ។ អវិជ្ជាគឺមកពីមិនដឹងមិនយល់ហេតុនៃទុក្ខ ។ តណ្ហាគឺចំណង់ចង់បាននូវអ្វីៗគ្រប់យ៉ាងមានកាមតណ្ហា ចំណងជាដើម ។
- និរោធអរិយសច្ចៈ ៖ សភាពពិតក្នុងការរំលត់ទុក្ខ ដោយបំបាត់អវិជ្ជាជាប្រភពដើមនៃទុក្ខ ។
- មគ្គអរិយសច្ចៈ ៖ វិធីរំលត់ទុក្ខប្រកបដោយមគ្គ (ត្រូវ ) មាន៨ យ៉ាងគឺហៅថា ***អដ្ឋង្គិកមគ្គ*** ៖

១. សម្មាទិដ្ឋិ = ការមានទស្សនៈត្រូវ
២. សម្មាសង្កប្បៈ = ការគិតត្រូវ
៣. សម្មាវាចា = ការនិយាយត្រូវ
៤. សម្មាកម្មន្តៈ = ការធ្វើអំពើត្រូវ
៥. សម្មាអាជីវៈ = ការចិញ្ចឹមជីវិតត្រូវ
៦. សម្មាវាយាម = ការព្យាយាមត្រូវ
៧. សម្មាសតិ = ការមានសតិត្រូវ
៨. សម្មាសមាធិ = ការធ្វើ ឬការតាំងចិត្តត្រូវ

ដែលយើងអាចសង្រួមមកបានជា ***សីល សមាធិ និង បញ្ញា*** [6]។

# ២.តួនាទីព្រះពុទ្ធសាសនាក្នុងការអប់រំផ្នែកសីលធម៌

លីលធម៌ជាសម្បទាមួយយ៉ាងសម្រាប់មនុស្សគ្រប់រូប ដែលជាផលតបស្នងប្រកបដោយតម្លៃ សេចក្តីថ្លៃថ្នូរ កិត្តិយស កេរ្តិ៍ឈ្មោះក្រអូបសុះសាយ ក៏ព្រោះតែមនុស្សគ្រប់រូបមានសីលធម៌ជាគោលលសម្រាប់ប្រណិបត្តន៍ក្នុងដំណើរជីវិតរបស់ខ្លួន ។ ក្រៅពីចំណេះ ជំនាញ សីលធម៌ជាសូចនាករមួយយ៉ាងសំខាន់ក្នុងការលើកស្ទួយនូវតម្លៃមូលដ្ឋានរបស់មនុស្ស ។ ពុទ្ធសាសនា ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជម្រុញ និង ជាថ្នាលបណ្តុះបណ្តាលសីលធម៌សង្គម

[6] ក្រសួងអប់រំយុវជន និងកីឡា **អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២** បោះពុម្ពឆ្នាំ ២០១៣ ទំព័រទី ៨៦

សម្រាប់ប្រជាជនកម្ពុជាតាំងពីបុរាណកាលមក ដែលយើងមិនអាចមើលរំលងនូវតម្លៃនៃសាសនាព្រះពុទ្ធ ក្នុងការអប់រំផ្នែកសីលធម៌នេះជាចាំបាច់ ។ ស្របពេលបច្ចុប្បន្ននេះ ទាំងរដ្ឋាភិបាលក្តី សង្គមស៊ីវិលក្តី មហាជនក្តី បានយកចិត្តទុកដាក់ជាសំខាន់លើការអប់រំសីលធម៌ ហើយក្នុងនោះ សាសនាព្រះពុទ្ធជាកតាលីករយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាល អប់រំ និងលើកស្ទួយសីលធម៌សង្គមឲ្យមានភាពល្អប្រសើរ ។

## ២.១.និយមន័យសីលធម៌

សីលធម៌ គឺជាសីលដែលជាធម៌របស់សត្វលោក ឬសីលនិងធម៌ កិរិយាមាយាទ សណ្តាប់ធ្នាប់ ដំបូន្មានដែលនាំឲ្យជៀសវាងអំពើអាក្រក់ហើយឲ្យប្រព្រឹត្តតែអំពើល្អ [7]។

សីលធម៌ សំដៅទៅលើវិន័យក្រិត្យក្រម សម្រាប់អប់រំខ្លួន ឲ្យប្រព្រឹត្តកាយ វាចា ចិត្ត វៀរចាកនូវអំពើបាប ឬអំពើអាក្រក់ [8]។

ជារួមមកវិញ សីលធម៌ សម្គាល់នូវទ្រឹស្តី និងពាក្យទូន្មានទាំងឡាយណា ដែលដឹកនាំទៅរកផ្លូវល្អ ចៀវវាងផ្លូវអាក្រក់សម្រាប់ការរស់នៅឲ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយល្អសម្រាប់ខ្លួនឯង គ្រួសារ ការងារ សង្គមជាតិ និងពិភពលោកទាំងមូល ។

### ក. សីលធម៌ផ្ទាល់ខ្លួន

- ការដឹងខុស ដឹងត្រូវ ការស្គាល់ល្អ ស្គាល់អាក្រក់ និងទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន
- មិនលើកតំកើងខ្លួនក្លាហានក្នុងផ្លូវត្រូវ
- ការតាំងខ្លួនជាម្ចាស់ចិត្តរបស់ខ្លួន
- ការនិយាយត្រឹមត្រូវ
- វៀរចាកអំពើអបាយមុខ ។ល។

### *ខ. សីលធម៌ក្នុងគ្រួសារ*

- ឪពុកម្តាយចិញ្ចឹមកូនដោយពុំនឹកគិតពីការតបស្នងសងគុណមកវិញទេ
- ឪពុកម្តាយស្រឡាញ់កូនស្មើៗគ្នា
- ឪពុកម្តាយធ្វើឲ្យកូនមានសុខដុមក្នុងគ្រួសារ
- ឪពុកម្តាយអប់រំកូនឲ្យក្លាយជាពលរដ្ឋល្អ
- កូនស្រឡាញ់ ស្តាប់ដំបូន្មានឪពុកម្តាយ
- ផ្គត់ផ្គង់គ្រឿងឧបភោគ បរិភោគដល់លោកទាំងពីរ និងថែរក្សាសុខភាពលោកទាំងពីរ ។

### *គ. សីលធម៌ក្នុងការងារវិជ្ជាជីវៈ*

---

[7] សម្តេចសង្ឃរាជ ជួន ណាត **វចនានុក្រមខ្មែរភាគ១ ភាគ២** បោះពុម្ពឆ្នាំ ១៩៦៧ ទំព័រទី ១៣៦១

[8] បណ្ឌិត ជា វណ្ណី **តម្លៃអប់រំនៃការបណ្តុះធម្មចរិយា** បោះពុម្ពឆ្នាំ ២០២២ ទំព័រទី ៨

- មានមនសិការការងារ
- ការប្រកបរបរការងារតាមសមត្ថភាព
- ការប្រកបមុខរបរសុចរិត មិនលួចប្លន់ ភូតភរ បោកប្រាស់ កេញចំណេញគេ
- អ្នកមានអំណាចមិនរំលោភអ្នកគ្មានអំណាច
- ការធ្វើការឲ្យស្របនឹងកម្លាំង សមត្ថភាព និង ស្របច្បាប់សង្គម ។ល។

*ឃ. សីលធម៌ក្នុងសង្គម*

- ការរួបរួមសាមគ្គីគ្នា
- មិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន
- ត្រូវចេះគោរពនិងឲ្យតម្លៃអ្នកដទៃ
- ជួយសម្រាលទុក្ខដល់អ្នកជួបការលំបាក
- ការទទួលស្គាល់ទុក្ខលំបាករបស់អ្នកដទៃ
- ការមិនឈ្លានពានអ្នកដទៃ
- គ្មានការរើសអើងវណ្ណៈ និងមិនប្រកាន់ពូជសាសន៍ [9]។ល។

*ង. សីលធម៌ក្នុងសកលលោក*

ការរួមរស់ជាមួយនឹងប្រទេសលើសកលលោកដោយសន្តិភាព ។ ក្នុងន័យនេះបើមនុស្សម្នាក់ៗ ឬសង្គមនីមួយៗមិនបំពានគ្នា យកប្រៀបលើគ្នា យកឈ្នះយកចាញ់គ្នា កេងចំណេញពីគ្នា នោះសន្តិភាព និង សុភមង្គលនឹងកើតមានជាក់ជាពុំខាន [10] ។

- ការរាប់អានគ្នាដោយមិនរើសអើង ឬប្រកាន់ពូជសាសន៍ សាសនា សញ្ជាតិ ពណ៌សម្បុរ....
- រួបរួមសហការគ្នាក្នុងទិសដៅពង្រឹងវប្បធម៌ សន្តិភាព
- ដោះស្រាយបញ្ហាដោយសន្តិវិធីមិនប្រើអំពើហិង្សា
- សាមគ្គីភាព និង អន្តរជាតិ ( ក្នុងប្រទេស ក្នុងតំបន់ និងពិភពលោក ) [11] ។

## ២.២. សីលធម៌ក្នុងមង្គលធម៌ទាំង៣៨ប្រការ របស់ព្រះពុទ្ធសាសនា

១.កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ (អសេវនា ចពាលានំ )

២.កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ (បណ្ឌិតានញ្ច សេវនា )

៣.កិរិយាបូជាដល់បុគ្គលដែលគួរបូជា (បូជា ចបូជនីយានំ )

៤.កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ (បដិរូបទេសវាសោច )

៥.ភាវៈនៃអ្នកបានធ្វើបុណ្យទុកហើយក្នុងកាលមុន ( បុព្វេ កតបុញ្ញតា )

---

[9] ក្រសួងអប់រំ យុវជននិងកីឡា **សិក្សាសង្គមថ្នាក់ទី១០** បោះពុម្ពឆ្នាំ ២០១០ ទំព័រទី ២១៣

[10] បណ្ឌិត ជា វណ្ណី **តម្លៃអប់រំនៃការបណ្តុះធម្មចរិយា** បោះពុម្ពឆ្នាំ ២០២២ ទំព័រទី ១១

[11] ក្រុមនិស្សិតទី៦ (Rule) បង្រៀនដោយ គង់ ភូមីកា **សីលធម៌នៅក្នុងសង្គមខ្មែរ** បោះពុម្ពឆ្នាំ....ទំព័រទី១០

៦.កិរិយាតម្កល់ខ្លួនទុកដោយប្រពៃ (អត្តសម្មាបណីធិ ច )
៧.ភាវៈជាបុគ្គលបានស្តាប់បានរៀនសូត្រចេះដឹងច្រើន (ពាហុសច្ចុ )
៨.សេចក្តីឆ្លៀវឆ្លាតប៉ិនប្រសប់ក្នុងសិល្បៈទាំងពួង ( សិប្បៈ )
៩.វិន័យដែលបុគ្គលបានសិក្សាហើយដោយប្រពៃ ( វិនយោ ចសុសិក្ខិតោ )
១០.វាចាដែលបុគ្គលពោលដោយប្រពៃ ( សុភាសិតា ច យា វាចា )
១១.កិរិយាបម្រើ ឬ ទំនុកបម្រុងមាតា (មាតាបិតុ ឧបដ្ឋានំ )
១២.កិរិយាបម្រើ ឬ ទំនុកបម្រុងបិតា (មាតាបិតុ ឧបដ្ឋានំ )
១៣.កិរិយាសង្គ្រោះបុត្រ និងភរិយា (បុត្តទារស្សសង្គហោ )
១៤.ការងារទាំងឡាយដែលមិនច្របូកច្របល់ ( អនាកុលា ចកម្មន្តា )
១៥.កិរិយាបរិច្ចាគទាន (ទានំ )
១៦.កិរិយាប្រព្រឹត្តធម៌ដ៏ប្រសើរ (ធម្មចរិយា )
១៧.កិរិយាសង្គ្រោះញាតិទាំងឡាយ ( ញាតកានញ្ច សង្គហោ )
១៨.កិរិយាប្រកបការងារទាំងឡាយដែលមិនមានទោស ( អនវជ្ជានិ កម្មានិ )
១៩.កិរិយាមិនត្រេកអរក្នុងបាបនិងកិរិយាវៀរចាកបាប ( អារតី វិរតីបាបា )
២០.សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ( មជ្ជបានា ច សញ្ញាមោ )
២១.ការមិនប្រមាទក្នុងធម៌ទាំងឡាយ ( អប្បមាទោ ចធម្មេសុ )
២២.កិរិយាគោរពចំពោះបុគ្គលដែលគួរគោរព ( គារវោ ច )
២៣.កិរិយាប្រព្រឹត្តបន្ទាបខ្លួន( និវាតោ ច )
២៤.សេចក្តីសណ្តោសត្រេកអរចំពោះរបស់ដែលមាន (សន្តុដ្ឋី ច )
២៥.ភាពជាអ្នកដឹងឧបការគុណដែលអ្នកដទៃធ្វើហើយដល់ខ្លួន ( កតញ្ញូតា )
២៦.កិរិយាស្តាប់នូវធម៌តាមកាល ( កាលេន ធម្មស្សវនំ )
២៧.សេចក្តីអត់ធ្មត់ (ខន្តិ ច )
២៨.ភាវៈនៃបុគ្គលដែលទូន្មានប្រៀនប្រដៅបានដោយងាយ (សោវចស្សតា )
២៩.កិរិយាបានឃើញ បានជួបនូវសាមណៈទាំងឡាយដែលមានឥន្ទ្រីយ៍ស្ងប់រំងាប់ហើយ(សមណានញ្ច ទស្សនំ )
៣០.កិរិយាសន្ទនាសាកសួរនូវធម៌តាមកាល (កាលេនធម្មសាកច្ឆា)
៣១.សេចក្តីព្យាយាមដុតនូវបាបធម៌ ( តបោ ច )
៣២.កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ (ព្រហ្មចរិយញ្ច )
៣៣.កិរិយាឃើញនូវអរិយសច្ចធម៌ទាំងឡាយ(បរិយសច្ចាន ទស្សនំ )
៣៤.កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដោយបញ្ញាដ៏ខ្ពង់ខ្ពស់ ( និព្វានសច្ឆិរិយា ច )
៣៥.ចិត្តនៃបុគ្គលដែលមិនញាប់ញ័រដោយលោកធម៌ (ផុដ្ឋស្ស លោកធម្មេហិចិត្តំយស្ស ន កម្បតិ )
៣៦.ចិត្តនៃបុគ្គលមិនសោយសោកចំពោះអារម្មណ៍ (អសោកំ )

៣៧.ចិត្តដ៏បរិសុទ្ធ ស្អាតចាកកិលេស ( វីរជំ )

៣៨.ចិត្តក្សេមក្សាន្ត (ខេមំ)[12] ។

## ២.៣. ការអប់រំសីលធម៌តាមរយៈព្រះពុទ្ធសាសនា

សម្រាប់ពុទ្ធសាសនិក ត្រូវក្សោលីល ផ្តោតលើបញ្ចសីល ឬ និច្ចសីល មានជាអាទិ៍ ៖

**១.បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ៖** ករិយាមិនបៀតបៀន ឬយាយីជិវិតសត្វ
**២. អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ៖** កិរិយា មិនកាន់យករបស់ទ្រព្យ អ្នកដ៏ទៃ
**៣. កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ៖** កិរិយាមិនប្រព្រិត្តខុស នូវសីលធម៌ ក្នុងផ្លូវភេទ
**៤. មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ៖** កិរិយាមិនពោលពាក្យកុហក បោកបញ្ឆោតអ្នកដ៏ទៃ
**៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ៖** មិនសេពនូវទឹកស្រវឹង ឬគ្រឿងដែលធ្វើអោយប្រាជ្ញាថយចុះ។

## ២.៤. ការប្រណិបត្តន៍នូវកុសលកម្ម១០

*ក. កាយសុចរិត៣*

**១-បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺការសម្លាប់សត្វ។
**២-អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវរបស់ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា។
**៣-កាមេសុមិច្ឆាចារា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

*ខ. វចីសុចរិត៤*

**១-មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលពាក្យកុហក។
**២-បិសុណាវាចា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលពាក្យញុះញង់ ស៊កសៀតបំបែកបំបាក់អ្នកដទៃ។
**៣-ផរុសវាចា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលពាក្យអាក្រក់ ទ្រគោះបោះបោកជេរប្រទេចជាដើម។
**៤-សម្ផប្បលាបា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលពាក្យរោយរាយឥតប្រយោជន៍។

*គ.មនោសុចរិត៣*

**១-អនភិជ្ឈា** មិនមានចិត្តសំឡឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយគិតបម្រុងនឹងឲ្យមកជារបស់ខ្លួន។
**២-អព្យាបាទ** មិនមានចិត្តចងគំនុំគុំគួន គឺប៉ងចង់ឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស។
**៣-សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវ ហើយប្រកាន់ថាពិតជាត្រឹមត្រូវមែន [13]។

## ២.៥. ការស្គាល់ពីតួនាទីរបស់ខ្លួន

នៅក្នុងព្រះពុទ្ធសាសនា បានណែនាំឲ្យបុគ្គលស្គាល់ពីតួនាទីរបស់ខ្លួន ដើម្បីជាប្រយោជន៍យកទៅប្រតិបត្តិប្រចាំថ្ងៃ ។ ចំពោះការស្គាល់តួនាទីនេះទៀតសោត ទោះជាយើងជាអ្នកណា ឬនៅទីណាក៏ដោយ គឺសុទ្ធតែមានការបែងចែកតួនាទី សម្រាប់បុគ្គលគ្រប់រូបប្រកាន់ភ្ជាប់ក្នុងជីវភាពរស់នៅផងដែរ ។ ប្រសិនណាយើងមិនស្គាល់និងបានបែងចែក

[12] https://km.wikipedia.org/wiki/
[13] https://khmerbuddhism.wordpress.com/2012/01/20/

តួនាទីរបស់ខ្លួនឲ្យបានច្បាស់លាស់នោះទេ  វារមែងតែងតែមានការពិបាកនៅក្នុងការចាត់ចែងធ្វើការងារទូទៅជាប្រចាំ ហើយបើយើងបានយល់ដឹងនូវតួនាទីទាំងនោះ នោះវារមែងតែងតែនាំមកនូវភាពថ្កុំថ្កើងរុងរោចន៍ ។

**ក. តួនាទីមាតាបិតា**

**ទី១៖** មាតាបិតាគប្បីហាមកូនឲ្យវៀរអំពើបាប ។
**ទី២៖** ញ៉ាំងកូនឲ្យតម្កល់នៅក្នុងកុសលធម៌ ។
**ទី៣៖** គប្បីអប់រំកូនឲ្យពេញចិត្តក្នុងការសិក្សារៀនសូត្រ ។
**ទី៤៖** រៀបចំគូស្រករទៅតាមប្រពៃណី ។
**ទី៥៖** ចែកទ្រព្យសម្បត្តិឲ្យជាដើមទុន ។

**ខ. តួនាទីបុត្រធីតា**

**ទី១៖** ត្រូវចិញ្ចឹមបីបាច់ថែរក្សាមាតាបិតា ។

ទី២៖ ជួយធ្វើការដែលមាតាបិតាត្រូវការ។
ទី៣៖ រក្សាកេរ្តិ៍ឈ្មោះលើកតម្កើងពូជពង្សវង្សត្រកូល។
ទី៤៖ បម្រើមាតាបិតាដោយសុចរិតអោនលំទោន ។
ទី៥៖ បុត្រធីតាគប្បីសិក្សាថា អាត្មាអញត្រូវធ្វើបុណ្យឧទ្ទិសទក្ខិណាទានដល់មាបុតាបិតា។

**គ. តួនាទីស្វាមី**

**ទី១៖** ប្រដៅសព្វសារពើ ពោលពាក្យពិរោះសរសើរ ដោយលក្ខណៈប្រព្រឹត្តជាប្រយោជន៍ដល់ភរិយា ។
**ទី២៖** មិនមើលងាយជេរវាយភរិយាដូចទាសាទាសីកម្មករឡើយ។
**ទី៣៖** មិនប្រព្រឹត្តកន្លងភរិយា មិនត្រូវប្រព្រឹត្តគំនិតក្បត់ ព្រំដែនជាប្តី ។
**ទី៤៖** ប្រគល់នូវរបស់របរទាំងពួង ឲ្យមានឥស្សរភាពដល់ភរិយា ប្រគល់អំណាចឲ្យជាធំ ជាស្ត្រីមេផ្ទះ ជាស្ត្រី។
**ទី៥៖** ស្វាមីគប្បីរៀបចំឲ្យមានអលង្ការដល់ភរិយា។

**ឃ.តួនាទីភរិយា**

**ទី១៖** ចាត់ចែងការងារផ្ទះដោយផ្ចិតផ្ចង់ ។
**ទី២៖** សង្គ្រោះញាតិខាងស្វាមី នឹងខាងខ្លួនឯងដោយប្រពៃ ។
**ទី៣៖** គប្បីថែទាំទ្រព្យសម្បត្តិដែលប្តីរកបានមិនឲ្យវិនាសខូចខាតបាត់បង់ដោយការមិនគួរ ។
**ទី៤៖** មិនប្រព្រឹត្តកន្លងចិត្តប្តី គឺមិនត្រូវយកកំពូលស្នេហាទៅប្រគល់ឲ្យបុរសដទៃក្រៅពីស្វាមីខ្លួនឡើយ ។
**ទី៥៖** ភរិយាគប្បីឈ្លាសវៃក្នុងការងារទាំងឡាយរបស់ស្ត្រី មិនត្រូវខ្ជិលច្រអូស ។

**ង. តួនាទីគ្រូបាចារ្យ**

**ទី១៖** ដឹកនាំសិស្សឲ្យល្អដោយសុទ្ធចិត្ត ។
**ទី២៖** បង្ហាត់បង្រៀនសិស្សដោយល្អ ញ៉ាំងសិស្សឲ្យរៀនល្អ ។
**ទី៣៖** គ្រូអាចារ្យគប្បីបង្ហាត់សិល្បៈវិទ្យាឲ្យអស់ចំណេះ ។
**ទី៤៖** លើកតម្កើងសិស្សក្នុងទីប្រជុំ ។
**ទី៥៖** ធ្វើសេចក្តីការពារសិស្សគ្រប់ទិសទាំងឡាយ ។

**ខ. តួនាទីសិស្ស**

**ទី១៖** ក្រោកឈរទទួលក្នុងវេលាដែលគ្រូបាអាចារ្យដើរមក

**ទី២៖** គាល់បម្រើគ្រូអាចារ្យដោយចិត្តស្មោះស ។

**ទី៣៖** ជឿស្តាប់ឪវាទលោកទូន្មានប្រៀនប្រដៅដោយល្អចំពោះបញ្ហាណាមួយ យើងគួរគូសចំណាំក្នុងចិត្ត ហើយត្រូវត្រិះរិះមើលផងបើឃើញថាត្រូវល្អប្រញាប់ប្រតិបត្តិធ្វើតាម។

**ទី៤៖** ប្រណិប័តន៍ដោយធ្វើការងារជួយគ្រូអាចារ្យ។

**ទី៥៖** សិស្សគប្បីសិក្សាថា អាត្មាអញត្រូវរៀនសិល្បវិជ្ជាអំពីលោកគ្រូអាចារ្យដោយសេចក្តីគោរព។

**ច.តួនាទីចៅហ្វាយនាយ**

**ទី១៖** ចាត់ចែងការងារឲ្យធ្វើតាមសមគួរដល់កម្លាំង,

**ទី២៖** ឲ្យភោជនាហារ និងថ្លៃឈ្នួល និងរង្វាន់ដោយត្រឹមត្រូវដល់អ្នកបម្រើ ។

**ទី៣៖** ព្យាបាលក្នុងវេលាមានជម្ងឺ

**ទី៤៖** ចែកភោជនាហារដែលមានឱជារសប្លែកៗឲ្យបរិភោគ ភោជនាហារគាប់ប្រសើរប្លែកៗ

**ទី៥៖** បើកឲ្យសប្បាយក្នុងការគួរ

**ឆ.តួនាទីអ្នកបម្រើការងារ**

**ទី១៖** ក្រោកឡើងធ្វើការមុនចៅហ្វាយនាយ។

**ទី២៖** លែងធ្វើការងារក្រោយចៅហ្វាយនាយ ។

**ទី៣៖** កាន់យកតែរបស់ណាដែលចៅហ្វាយនាយឲ្យប៉ុណ្ណោះ។

**ទី៤៖** ធ្វើការងារដោយយកចិត្តទុកដាក់ ពោលគឺធ្វើការងារឲ្យបានល្អ

**ទី៥៖** នាំកិត្តិគុណចៅហ្វាយនាយទៅពោលសរសើរក្នុងទីដទៃ។

**ជ.តួនាទីមិត្ត**

**ទី១៖** ឲ្យដែលអ្វីដែលគួរឲ្យដល់មិត្តសម្លាញ់ ។

**ទី២៖** មិត្តល្អគប្បីសិក្សាថា អាត្មាអញគប្បីនិយាយពិរោះ ។

**ទី៣៖** មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវធ្វើប្រយោជន៍ដល់មិត្

**ទី៤៖** មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវសង្គ្រោះមិត្តសម្លាញ់ដោយមិនលើកតម្កើងខ្លួន ។

**ទី៥៖** មិត្តល្អគប្បីសិក្សាថា អាត្មាអញមិននិយាយបោកបញ្ឆោត [14]។

## ៣.តួនាទីព្រះពុទ្ធសាសនាក្នុងការអប់រំនៃចរិយាធម៌

### ៣.១. និយមន័យចរិយាធម៌

ចរិយា មានន័យថា ការប្រព្រឹត្ត សំណាង ព្រេង ព្រេងសំណាង [15]។

[14] https://vansary.blogspot.com/p/blog-page_68.html

[15] សម្តេចសង្ឃរាជ ជួន ណាត **វចនានុក្រមខ្មែរភាគ១ ភាគ២** បោះពុម្ពឆ្នាំ ១៩៦៧ ទំព័រទី ១៨៩

ធម៌ ជាសភាវៈដែលទ្រទ្រង់សត្វលោក គឺបុណ្យ បាប សុចរិត ទុច្ចរិត ។ល។ [16]

ដូច្នេះ ចរិយាធម៌សំដៅទៅដល់ សភាវៈទាំងឡាយណាដែលទ្រទ្រង់សត្វលោកក្នុងការប្រព្រឹត្ត អំពើ កម្ម ជាផលសំណាង ព្រេងសំណាងរបស់មនុស្សគ្រប់រូបដែលបានប្រព្រឹត្ត ។

**ចរិយាធម៌** មានន័យថាការប្រព្រឹត្តត្រឹមត្រូវ ខាងផ្លូវកាយ វាចា ចិត្ត ។ ចរិយាធម៌គឺសង្កត់ធ្ងន់ទៅលើគោលធម៌ប្រតិបត្តិហៅថា កល្យាណធម៌ ឬ បញ្ចសីល ជាធម៌ដ៏បរិសុទ្ធគ្រឿងតុបតែងកាយមនុស្សឲ្យមានសម្រស់ផូរផង់ ពន្លឺចែងចាំក្លិនក្រអូបសុសសាយ មានកេរ្តិ៍ឈ្មោះពីរោះរន្ទឺ រស់នៅសុខស្រួលហើយមានប្រាំចំណុចគឺ ៖

- **មេត្តា** ៖ គិតចង់ឲ្យគេបានសុខនិងករុណាចង់ឲ្យគេប្រាសចាកទុក្ខ ។
- **សម្មាអាជីវៈ** ៖ ចិញ្ចឹមជីវិតប្រពៃ ។
- **សទារសន្តោស** ៖ សន្តោសគឺត្រេកអរចំពោះភរិយាខ្លួន ។
- **សច្ចៈ** ៖ ប្រព្រឹត្តខ្លួនជាមនុស្សពិត ត្រង់ ។
- **សតិ** ៖ មានស្មារតីបរិបូណ៌ [17]។

ចរិយាធម៌ ជាការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ដែលជាចន្ទល់ដ៏រឹងមាំ ក្នុងការដឹកនាំដំណើរជីវិតប្រព្រឹត្តក្នុងផ្លូវត្រូវ ផ្លូវសុខក្នុងលោក ទាំងក្នុងបច្ចុប្បន្ន និងអនាគតដោយព្យាយាមរាំងខ្ទប់នូវផ្លូវអាក្រក់និងផ្លូវអបាយមុខទាំងឡាយ [18] ។

## ៣.២. ការប្រតិបត្តិនូវចរិយាធម៌

ការប្រព្រឹត្តនូវចរិយាធម៌ មាននូវ សុជីវធម៌ ព្រហ្មវិហារធម៌ និង គុណធម៌ ៖

### *ក. ការលើកកម្ពស់ការអប់រំនូវសុជីវធម៌*

សុជីវធម៌មានន័យថាក្រឹត្យក្រម ច្បាប់វិន័យអប់រំដើម្បីឲ្យបុគ្គលមានភាពជាមនុស្សប្រពៃ ។

សុជីវធម៌ គឺការរបៀបរស់នៅត្រឹមត្រូវ មាន ឥរិយាបថ ប្រកបដោយសណ្ដាប់ធ្នាប់ល្អ ដោយចេះប្រមាណគ្រប់អំពើ និង សកម្មភាពទៅតាមកាលៈទេសៈ ចេះធ្វើគារវកិច្ចក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សគ្រប់ប្រភេទក្នុងសង្គម។គេអាចសង្កេតឃើញថា សុជីវធម៌ ជាផ្នែកមួយនៃសីលវិជ្ជាផង និង សោភ័ណវិជ្ជាផង។ មនុស្សដែលមានសុជីវធម៌ តែងតែចេះបង្ហាញឥរិយាបថ ចរិតមាយាទ និងចរិយាសម្បត្តិល្អ។ ដើម្បីស្វែងយល់ពីចរិតមាយាទមនុស្សម្នាក់ៗ យើងត្រូវសិក្សាចរិយាសាស្ត្រ។ ចរិយាសាស្ត្រ គឺជាគម្ពីរឬក្បួនខ្នាតដែលចែងអំពីផ្នត់គំនិត, ចរិយាសម្បត្តិ, និងចរិតលក្ខណៈរបស់មនុស្ស [19]។

សុជីវធម៌រួមបញ្ចូលនូវការអប់រំផ្សេងៗដូចជា ៖

- ការប្រើប្រាស់ពាក្យពេចន៍ និងការប្រព្រឹត្តកិរិយាឲ្យសមសួនតាមវ័យ តាមឋានៈ តាមទីកន្លែងជាដើម។

---

[16] សម្ដេចសង្ឃរាជ ជួន ណាត **វចនានុក្រមខ្មែរភាគ១ ភាគ២** បោះពុម្ពឆ្នាំ ១៩៦៧ ទំព័រទី ៤៨១

[17] ភិក្ខុ **សំអ៊ាន សារុន**

[18] បណ្ឌិត ជា វណ្ណី **តម្លៃអប់រំនៃការបណ្ដុះធម្មចរិយា** បោះពុម្ពឆ្នាំ ២០២២ ទំព័រទី ៣

[19] https://thmeythmey.com/?

- ការរៀនទទួលខុសត្រូវចំពោះមុខនាទីរបស់ខ្លួន ។
- ការទទួលស្គាល់ដឹងថាខ្លួនជាផ្នែកមួយនៃសង្គម ។

យ៉ាងណាមិញសុជីវធម៌ត្រូវបានបែកចែកជាច្រើនប្រភេទដូចជា ៖

- សុជីវធម៌សម្រាប់ខ្លួនឯង
- សុជីវធម៌ក្នុងគេហដ្ឋាន
- សុជីវធម៌ក្រៅគេហដ្ឋាន
- សុជីវធម៌ក្នុងអាជីវកម្មការងារ
- សុជីវធម៌ក្នុងភាសា
- សុជីវធម៌ជប់លៀងភោជនីអាហារ
- សុជីវធម៌ពិធីបុណ្យនៅគេហដ្ឋាន[20] ។

### *ខ.ការលើកកម្ពស់ការអប់រំគុណធម៌*

គុណធម៌មានន័យថា ការប្រព្រឹត្តអំពើល្អប្រសើរ ចំពោះអ្នកដទៃដែលជាអំពើនាំមកនូវភាពចម្រុងចម្រើនកាន់តែច្រើន ដែលគេផងរាល់គ្នាគោរព កោតសរសើរ ហើយក៏មានទឹកចិត្តកត្តញ្ញូ ចង់តបស្នងធ្វើនូវអំពើល្អនោះត្រឡប់ទៅវិញបន្ថែមបន្តទៀត ដោយទឹកចិត្តជ្រះថ្លាពីក្នុងចិត្ត ក្នុងបេះដូងរបស់គេ ។ គុណធម៌សំដៅលើអំពើល្អរបស់មនុស្សដែលពលរដ្ឋដទៃទៀតនៅក្នុងសង្គម ដូចជា សង្គមគ្រួសារ សង្គមការងារ សង្គមជាតិ ជាដើម ។

ការប្រព្រឹត្តអំពើជាគុណធម៌មាន ៖

- ការលើកទឹកចិត្តចេះជួយឈឺឆ្អាល យល់សុខទុក្ខគ្នា ជួយហុចដៃផ្តល់គំនិតយិតយោងគ្នា ចេះចែករំលែកគ្នាពេលមានអាសន្នអន្តរក្រ ខ្វះខាត ឬទុក្ខលំបាកនានា ។
- ការមិនឈរមើលបំណាំគ្នា និងចាប់កំហុសគ្នា ទៅវិញទៅមក ។
- ការនិយាយស្តីក្នុងន័យផ្តល់កម្លាំងចិត្ត ពេលពេលមនុស្សបាក់ទឹកចិត្ត ឬ ប្រទះការលំបាកផ្លូវចិត្តដោយប្រការណាមួយ ។
- ការជួយជាស់តឿន បង្រៀន រំលឹក ណែនាំគ្នាឲ្យបានល្អប្រសើរចេះគិតវិជ្ជមាន ហើយរីកចម្រើន ។
- ការចង្អុលបង្ហាញ ឬ ដឹកដៃប្រាប់នូវប្រភពល្អៗ ដល់ពលរដ្ឋ គ្រួសារ ឬ សង្គមជាតិ ឲ្យចេះជួយខ្លួនឯងរៀនស្វែងរកផ្លូវប្រសើរក្នុងជីវិត សម្រាប់ដើរ ដូចជាការសិក្សា ការមានមុខរបរ ឬ មុខជំនាញ សម្រាប់កាត់បន្ថយភាពខ្វះខាត ក្នុងគ្រួសារក៏ដូចជាសង្គមជាតិ ។
- ការមានសេចក្តីសន្តោសមេត្តា និងមានសប្បុរសធម៌ដល់ជនពិការ ទុគតជន កុមារកំព្រា ជនដែលមានជំងឺសតិមិនល្អ ឬចាស់ជរា ឬមនុស្សដែលគ្មានទីពឹងមិនអាចជួយខ្លួនឯងបាន ។

[20] អ្នកស្រី ភី ជៀនឡាយ **កម្រងសុជីវធម៌** បោះពុម្ពឆ្នាំ ១៩៧០

- ការផ្តល់វិជ្ជា ការអប់រំ ការថែទាំ ការរក្សាមនុស្សឲ្យចាកផុតពីការប្រព្រឹត្តអំពើអាក្រក់ជាដើម [21]។

*គ. ការលើកកម្ពស់ការអប់រំផ្នែកព្រហ្មវិហារធម៌*

ព្រហ្មវិហារធម៌ ជាធម៌របស់ព្រះព្រហ្មដែលក្រាលចិត្តសន្តោសប្រោសប្រណីចំពោះគ្រប់មនុស្សសត្វដោយគ្មានការរើសអើង ។ ព្រហ្មវិហារធម៌ជាធម៌ដ៏ទីនៅរបស់ព្រះព្រហ្ម ជាធម៌ប្រតិបត្តិដើម្បីឲ្យមនុស្សរស់នៅបានសេចក្តីល្អប្រសើរដែលប្រជាជនគ្រប់ស្រទាប់វណ្ណៈនឹងត្រូវប្រណិបត្តន៍ដើម្បីសាមគ្គីភាពនិងសុខក្សេមក្សាន្តក្នុងគ្រួសារនិងសង្គម [22] ។

ជាតុរបស់ព្រហ្មវិហារមាន ៖

- មេត្តាៈ សេចក្តីស្រលាញ់រាប់អាន
- ករុណាៈ សេចក្តីអាណិតអាសូរ
- មុទិតាៈ មានចិត្តរីករាយនៅពេលឃើញគេបានសុខ
- ឧបេក្ខាៈ ការតាំងចិត្តនៅជាកណ្តាល។

# ៤. មធ្យោបាយក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និង ចរិយាធម៌

ជាទូទៅ ការផ្សព្វផ្សាយជារឿងមួយដ៏ចាំបាច់បំផុតក្នុងការបញ្ជ្រាបនូវការអប់រំផ្នែកសីលធម៌ និងចរិយាធម៌ក្នុងសង្គមខ្មែរ ។ យ៉ាងណាមិញ ការរកមធ្យោបាយផ្សព្វផ្សាយជារឿងមួយសំខាន់ សម្រាប់បង្ហូរនូវគុណតម្លៃនៃអ្វីដែលយើងចង់ផ្សព្វផ្សាយឲ្យមានប្រសិទ្ធភាពខ្ពស់ ។

## ៤.១.ការផ្សព្វផ្សាយជាធម្មទេសនា ឬ ជាធម្មទាន

ក្នុងបរិបទដែលប្រទេសកម្ពុជា ជាប្រទេសដែលមានប្រជាជនច្រើនលើសលប់ ប្រមាណជា ៩៥% [23] គោរពព្រះពុទ្ធសាសនា និង ត្រូវបានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៤៣ តាក់តែងនៅឆ្នាំ ១៩៩៣ បានចែងថា “ **ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ** ” ផងនោះ សរបញ្ជាក់ថា ប្រជាជនខ្មែរ មានជំនឿយ៉ាងមុតមាំលើទស្សនៈព្រះពុទ្ធសាសនា គោរពយ៉ាងជាប់លាប់ នូវពុទ្ធោវាទដែលបានចែងចងនៅក្នុងគម្ពីរ ព្រះត្រៃបិដក មាន ៨៤០០០ព្រះធម្មក្ខន្ធ និង រតនៈត្រៃ មានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីសក្ការៈ ។ ក្រោយពីព្រះពុទ្ធអង្គបានចូលបរិនិព្វានទៅ មានតែព្រះសង្ឃជាសារ៉ៃដ៏សំខាន់ ក្នុងការផ្សព្វផ្សាយនូវកងធម៌ទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធគ្រប់និគមជនបទ តាមរយៈការផ្តល់ជាឱវាទទេសនា អប់រំ បង្កប់ដោយទស្សនៈវិជ្ជា ចំណេះដឹង និងសីលធម៌ខ្ពង់ខ្ពស់ ដែលព្រះបរមគ្រូតែងប្រណិបត្តិតាំងពីទ្រង់បានត្រាស់ដឹង ។ ទេសនា ត្រូវបានប្រជាជនខ្មែរនិពន្ធបំផុត ដែលជាទំនៀមពីបុរាណកាលមក នៅក្នុងពិធីបុណ្យសាសនា ប្រពៃណី តែងមានព្រះសង្ឃ ទេសនាផ្តល់ជាគំនិត អប់រំ ក្រើនរំលឹកឲ្យពុទ្ធបរិស័ទដើរតាមគន្លងដ៏ត្រឹមត្រូវនៃព្រះពុទ្ធសាសនា ។ ក្នុងពិធីបុណ្យ កឋិនទាន បុណ្យផ្កាប្រាក់ បុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្ឌ បុណ្យមាឃបូជា ពិសាខបូជា បុណ្យ

---

[21] បណ្ឌិត ជា វណ្ណី **តម្លៃអប់រំនៃការបណ្តុះធម្មចរិយា** បោះពុម្ពឆ្នាំ ២០២២ ទំព័រទី ១៥

[22] ក្រសួងអប់រំយុវជននិងកីឡា ***សីលធម៌ពលរដ្ឋវិជ្ជា* ថ្នាក់ទី១១** បោះពុម្ពឆ្នាំ ២០១៩ ទំព័រទី ៦

[23] ក្រសួងធម្មការ និង សាសនា **ដែលផ្សព្វផ្សាយដោយផេកស្ថានទូតសហរដ្ឋអាមេរិកនៅកម្ពុជា**

ទេសនាមហាជាតកជាដើម ទេសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមៀងប្រមូលនូវការសង្រួមចិត្ត កាយ វាចា ដែលព្រះធម៌ ព្រះសង្ឃប្រៀបបាននឹងមាគ៌ានាំបរិស័ទឲ្យទទួលបានពុទ្ធិនិងកុសលកម្មនានា ។ ក្នុងកម្មវិធីទេសនានេះទៀតសោត គេបានរៀបចំកន្លែងទេសន៍ដ៏ល្អល្អះមានផ្កាថ្មី មានកៅអី តុ ប្រណិត មានរចនាលំអរដោយភ្លើងចម្រុះពណ៌ និងអាចទេសន៍គ្រែ១ គ្រែ២ គ្រែ៣..ជាដើម ។ ការទេសនាទៀតសោត ព្រះសង្ឃបានលើកយកនូវពុទ្ធប្រវត្តិ កំណើតព្រះពោធិសត្វ ឬ កងធម៌ណាមួយមកសម្តែងដែលទាក់ទងនឹងកម្មវិធី ។ ម្យ៉ាងវិញទៀតនោះ ព្រះអង្គក៏អាចបញ្ជ្រាបនូវមេរៀនអប់រំសីលធម៌ នានាសម្រាប់ឲ្យពុទ្ធបរិស័ទ្ធ ជាពិសេសយុវវ័យបានជ្រួតជ្រាបនូវគុណតម្លៃនៃសីលធម៌ ចរិយាធម៌សង្គម ព្រមទាំងយកមកអនុវត្តក្នុងជីវិតដ៏ល្អប្រសើរ ។

## ៤.២. ការផ្សព្វផ្សាយតាមបណ្តាញសង្គម

ពេលបច្ចុប្បនេះ ផ្នែកបច្ចេកវិទ្យាកាន់តែទំនើប ស្របនឹងយុគសម័យឌីជីថល និង គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល នៃយុទ្ធសាស្រ្តបញ្ចកោណនេះផងនោះ នាំឲ្យទំនើបកម្មនៃឧស្សាហកម្ម៤.០បានហក់ខ្ពស់លើសពីការរំពឹងទុក ។ ក្នុងនោះ យុវវ័យ ជាចំណែកមួយយ៉ាងធំដែលជម្រុញឲ្យវិស័យនេះរីកចម្រើនខ្លាំង ព្រោះពួកគាត់បានចំនាយពេលវេលាច្រើនជាមួយនឹងបច្ចេកវិទ្យា ។ ភាពអំណោយផលមួយនេះហើយដែលយើងអាចបញ្ជ្រាបនូវការអប់រំខ្លីៗ ទាក់ទងនឹងសីលធម៌សង្គម និងចរិយាធម៌ជាដើម ។ ជាក់ស្តែង សព្វថ្ងៃយើងបានឃើញផេក នៃបណ្តាញសង្គមរបស់ព្រះសង្ឃ វត្តអារាមនានា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយនូវគុណតម្លៃនៃសីលធម៌ ចរិយាធម៌នេះ ។ ក្នុងការប្រើប្រាស់បច្ចេកវិទ្យានេះទៀតសោត ធម្មទេសនាអាចថតជាសំឡេង ជាវីដេអូ ជារូបភាពកាត់តរូបភាពផ្តល់ជាគតិអប់រំខ្លីៗ ក្នុងការចែករំលែកក្នុងបណ្តាញសង្គម ។

## ៤.៣. ការផ្សព្វផ្សាយតាមការធ្វើសកម្មភាពផ្សេងៗ

ការធ្វើកម្មភាពផ្សេងៗ ដែលទាក់ទងនឹងការអប់រំសីលធម៌ ចរិយាធម៌ ដោយមានការចូលរួមពីព្រះសង្ឃ និងអាជ្ញាធរពាក់ព័ន្ធនានា ក្នុងការអប់រំ និងលើកស្ទួយតម្លៃសីលធម៌ និងចរិយាធម៌សង្គម មានអាទិ៍ ការចុះជួបផ្ទាល់នឹងសិស្សានុសិស្ស យុវជន ការរៀបចំកម្មវិធីអប់រំសីលធម៌ ចរិយាធម៌ គុណធម៌ តាមសហគមន៍ សាលារៀន ការប្រឡងប្រណាំង ការថតជាវីអេអូខ្លីអប់រំជាដើម ក្នុងការជម្រុញឲ្យយុវជន និងពុទ្ធសាសនិកចូលរួមដោយសកម្ម ដែលជាសូចនាករ និង នវានុវត្តភាពមួយដ៏សំខាន់ ។

## ៤.៤.ការផ្សព្វផ្សាយតាមរយៈអក្សរសិល្ប៍

ពុទ្ធសាសនា បានចូលរួមបង្កើតអក្សរសិល្ប៍ពុទ្ធនិយម ។ ពុទ្ធនិយមសុទ្ធសាធក្តី ក្លាយក្តី ក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអប់រំ ចំណេះដឹង ជាពិសេសផ្នែកសីលធម៌ ចរិយាធម៌ ។ ក្នុងទ្រឹស្តីនៃព្រះពុទ្ធសាសនា ត្រូវបានលោកអ្នកប្រាជ្ញទាំងនោះ យកមកបញ្ជ្រាបនៅក្នុងស្នាដៃរបស់ខ្លួនដោយចងក្រងជារូបភាពផ្សេងៗ ជាកំណាព្យ ជាពាក្យកម្រងកែវ ជាទំនុបច្រៀង សុភាសិតជាដើមប្រកបដោយសិល្បវិធីនិងភាពប៉ិនប្រសប់ពោរពេញដោយមនោគតិ ។ ក្រៅពីបង្កប់នូវទស្សនៈវិជ្ជា គោលលទ្ធិនៃសាសនា រឿងរ៉ាវជាសាស្ត្រាក្តី ជាតកនានាក្តី បានផ្សាំបណ្តុះនូវការអប់រំសីលធម៌ និង ចរិយាធម៌យ៉ាងឫត្យក្ស ។

តាមរយៈ**រឿងព្រះតេមិយ** ដែលជារឿងទី១ ស្ថិតក្នុងគម្ពីរទសជាតក ដែលព្រះពោធិសត្វយកកំណើតជាតេមិយ ។ ក្នុងជាតិនេះទៀតទ្រង់បានបំពេញនូវនេក្ខម្មបារមី ( អ្នកបួស ) ។ ពេលដែលទ្រង់ប្រសូតបានមួយខែ ត្រូវព្រះបិតា កាសិករាជ យកដាក់លើឧរូទ្រង់ ដើម្បីកាត់ទោសចោរចំនួន ៤នាក់ដោយ ចោរម្នាក់ត្រូវវាយរំពាត់ផ្តៅ១០០០ខ្នាប់ ចោរម្នាក់ដោតអណ្តាតឆ្កាង និងចោរម្នាក់ត្រូវចងដោយច្រវ៉ាក់ដាក់ក្នុងពន្ធនាគារ ចោរ

ម្នាក់ត្រូវចាក់ស្លាប់ដោយលំពែង ដែលធ្វើព្រះរាជកុមារភិតភ័យ និងគិតដល់អនាគតដែលត្រូវស្នងតំណែងពីព្រះបិតា និងប្រព្រឹត្តដូចបិតា ហើយនឹងរងនូវអំពើបាប ធ្លាក់នរក ទើបទ្រង់បានធ្វើជាពិការភាពជាគថ្លង់ខ្វិនខ្វង់តាមសម្ដីរបស់ម្ដាយដើមដែលរក្សាការពារស្វេតឆត្រទ្រង់ ។ តេមិយបានធ្វើអាការៈបែបនេះអស់រយៈវេលា១៦ឆ្នាំ ទោះបីព្រះបិតាពិសោធន៍ទាំង១៦មុខ ក៏មិនអាចធ្វើឲ្យតេមិយមកលក្ខណៈធម្មតាបាន ទើបព្រះបាទកាសិករាជ អស់ចិត្តឲ្យសារថី យកតេមិយកុមារទៅសម្លាប់ចោលក្នុងព្រៃ តែតេមិយបានធ្វើឲ្យសារថីភ្ញាក់ខ្លួន ព្រោះទ្រង់បានធ្វើរាងកាយឲ្យប្រក្រតី មាំមួន និងបានបួសនៅក្នុងព្រៃសន្សំកុសលកម្ម ដោយបរិសុទ្ធ ក្នុងឧត្តមភេទ ។ តេមិយបានពន្យល់ញាតិវង្ស ប្រជាជនទ្រង់ឲ្យយល់ពីកុសលកម្ម ការសាងអំពើល្អ រហូតដល់ញាតិវង្ស ប្រជាជនទ្រង់បានបួសគ្រប់ៗគ្នា និងបណ្ដាលចិត្តឲ្យនគរដទៃមកបួសសន្សំកុសលផងដែរ ។តាមរយៈរឿងតេមិយនេះ បាប ជម្រុញឲ្យយើងប្រកាន់ភ្ជាប់នូវគោលជំហរ ម្ចាស់ការលើខ្លួនឯង មានភាពអំណត់អត់ធន ចេះតស៊ូមានគោលដៅច្បាស់លាស់ និងចេះសាងកុសល សន្សំបុណ្យ សាងមិត្ត ព្រមទាំងការរំដោះខ្លួនចេះពីបាបកម្មដោយបញ្ញា សីល សមាធិ ។

**រឿងសុវណ្ណសាម** ជាពុទ្ធប្រវត្តិនៃព្រះពោធិសត្វដែលយាងយកកំណើតជាសុវណ្ណសាម ជាបុត្រឥសីទុកូល និងនាងបារិកា ។ សុវណ្ណសាមជាបុរសប្រកបដោយសីលធម៌ ចរិយាធម៌ខ្ពស់ ផ្សាយចេញនូវមេត្តាធម៌ ។ សេចក្ដីមេត្តារបស់សាមចំពោះសព្វសត្វមនុស្ស ជាពិសេសស្ដេចបិលយក្ខ បានជះផលដ៏ល្អសម្រាប់ទ្រង់គ្រួសារទ្រង់ និងមនុស្សនៅជុំវិញខ្លួន ។ ការផ្សាយចេញនូវមេត្តាធម៌ នាំមកនូវភាពសុខសាន្ត ភាពសុខដុមទាំងផ្លូវកាយ វាចា ចិត្ត ។ សាមទោះបីត្រូវធ្នូរបស់បិលយក្ខក្ដី តែពោលវាចាដោយមេត្តា បណ្ដាលចិត្តបិលយក្ខចេញមកសារភាព និងទទួលខុសត្រូវនូវទង្វើរបស់ខ្លួន ។ អំណាចនៃមេត្តាធម៌ នាំឲ្យសាមរួចពីសេចក្ដីស្លាប់ មាតាបិតាផុតពីពិការភាព និង បិលយក្ខបានសាងនូវអំពើល្អត្រឹមត្រូវជាកុសលមកវិញ ។

យ៉ាងណាមិញ **រឿងវេស្សន្តរ** បានបង្ហាញពីការបំពេញនូវ បញ្ចទាន របស់ទ្រង់ដើម្បីសម្រេចបាននូវការត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធនៃយើង ។ ទ្រង់បានលះបង់ទាំង អជ្ឈិត្តិកទាន ពាហិរទាន មាន ទ្រព្យបរិច្ចាគ កាយបរិច្ចាគ ជីវិតបរិច្ចាគ បុត្តបរិច្ចាគ និង ភរិយាបរិច្ចាគ ។ អំណាចនៃទាន ធ្វើឲ្យទ្រង់សម្រេចបំណង មគ្គផលទាំងឡាយ កើតចេញពីទាន ។វេស្សន្តរទ្រង់បានដាក់ទាននូវទ្រព្យសម្បត្តិ ជាច្រើនលើកច្រើនសារ ធ្វើនូវសត្តសតកមហាទាន ទ្រង់បានលះបង់នូវជីវិត កាយ បើសិនស្មូមយាចកណាមកសុំថែមទាំងបរិច្ចាគបុត្តឲ្យស្មូមជូជក និង មទ្រីឲ្យទៅស្មូមដែលជានិម្មិតកាយរបស់ព្រះឥន្ទ្រ ។ ការលះបង់ដ៏មហិមានេះ ពិតជាគ្មាននរណាធ្វើបានដូចទ្រង់ឡើយ ។ ទោះជាយ៉ាងក៏ដោយ ក៏នេះបង្ហាញឲ្យឃើញពីសភាវៈដែលមិនមែនជារបស់ខ្លួន មិនមែនអត្តៈ ហើយការធ្វើទាននេះទៀតសោត បង្ហាញពីការកសាងកុសល ប្រកបដោយព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់ដែលយើងគ្រប់គ្នា គួរផ្ដើមចែករំលែក ការចេះជួយគ្នា ទៅវិញទៅមកដោយសុទ្ធចិត្ត ។

ចំពោះ ស្នាដៃ**រឿងកាកី** របស់ព្រះអង្គឌួង បានបង្ហាញឲ្យឃើញតម្លៃនៃស្ត្រីខ្មែរ ប្រកបដោយភាពថ្លៃថ្នូរមិនប្រាថ្នាប្ដីពីរបី ដែលនាំឲ្យបាត់បង់នូវតម្លៃជាស្ត្រីខ្មែរ ហេតុការណ៍ដែលកាកី បានជ្រុលខ្លួនទាក់ទងមាណពប្រគល់ខ្លួនឲ្យគន្ធន ហើយត្រូវបានព្រះបាទព្រហ្មទត្ត យកទៅបណ្ដែតពោងពាយ រហូតដល់បាត់បង់ជីវិត នេះជាមេរៀនមួយសម្រាប់ស្ត្រីគ្រប់រូប ប្រកបដោយសីលធម៌ និង ចរិយាធម៌ ទោះបីជាការដាក់ពិន័យមានភាពព្រៃផ្សៃ តែឆ្លុះបញ្ចាំងឲ្យឃើញពីគុណតម្លៃរបស់ស្ត្រី ត្រូវមានភក្ដីភាព ចំពោះគ្រួសារ ស្វាមី ។ ក្នុងនោះក៏ជាកញ្ចក់ឆ្លុះបញ្ចាំងសម្រាប់បុរស មិនត្រូវយកប្រពន្ធកូនគេ កុំនិយាយកុហកបោកប្រាស់ដែលប្រាសចាកនូវបញ្ចសីល។

បើយើងមកមលើរឿង**សុបិនកុមារ** វិញ រឿងនេះឆ្លុះបញ្ចាំងពីអ្នកសាងល្អបានល្អ សាងអាក្រក់បានអាក្រក់ ដែលជាទស្សនកម្មផលក្នុងព្រះពុទ្ធសាសនា ។ ជាក់ស្ដែង ឪពុកសុបិនកុមារដែលជាអ្នកនេសាទនិងមិនរក្សាសីលនោះ បានស្លាប់ទៅធ្លាក់នរក ឯម្ដាយសុបិនកុមារ ដែលរារាំងកូនមិនឲ្យទៅបួសនោះត្រូវបានពួកយមបាលយកមកធ្វើទារុណកម្មបោះក្នុងភ្លើងជាដើម ។ ប៉ុន្តែអំណាចនៃការបួសរបស់សុបិនកុមារ បានផ្ដល់នូវអានិសង្ស និងការតបស្នងដោយឪពុកសុបិនកុមារ បានរួចផុតពីនរក ទៅកើតនៅឋានសួគ៌ ឯម្ដាយរួចផុតពីការធ្វើបាបរបស់ពួកយមបាល ។ នេះជាផលដែលកើតពីកម្ម ការសាងនូវកល្យាណកម្ម នាំបានកល្យាណផល តែបើសាងបាបកម្ម ក៏ទទួលនូវផលបាបដូចគ្នាដែរ។ ក្នុងហេតុផលនេះយើងត្រូវតែចូលរួមសាងនូវកុសលកម្ម១០ ដើម្បីទទួលបាននូវមគ្គផល និង អានិសង្សដ៏ខ្ពង់ខ្ពស់ ។

រឿង **សិរិធរ** ជាប្រភេទអក្សរសិល្ប៍ពុទ្ធនិយមមួយដែលបង្ហាញពីការធ្វើទានបាយរបស់សេដ្ឋីសិរិធរ ដល់ព្រះបច្ចេកពុទ្ធ ហើយបានកើតអាហារទិព្វ ហូបស្កប់ស្កល់ ចែករំលែកដល់អ្នកផងទាំងពួង ព្រមទាំងរស់នៅប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត ។ ក្នុងនេះ បង្ហាញពីទស្សនកម្មផលផងដែរ ដែលផលនៃអាហារទិព្វ ពេញបរិបូណ៌មិនចេះខ្វះនេះ ផ្ដើមចេញពីការធ្វើទានដ៏បរិសុទ្ធរបស់លោកសេដ្ឋី ហើយពេលលោកស្លាប់ទៅបានទៅកើតនូវស្ថានទេវលោក នេះជាផលកើតចេញពីកុសលកម្មនៃការធ្វើទានរបស់សេដ្ឋីសិរិធរ ។

# សន្និដ្ឋាន

ព្រះពុទ្ធសាសនា ជាចំណែកមួយដែលមិនអាចខ្វះបាន ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធនានា ក្នុងការជម្រុញ ធ្វើឲ្យមាននូវ នវានុវត្តភាពការងារទាក់ទងនឹង ការអប់រំ បណ្ដុះបណ្ដាលនូវសីលធម៌ ចរិយាធម៌ ក្នុងសង្គមខ្មែរជាពិសេសពេលបច្ចុប្បន្ន និង គោលដៅបណ្ដុះទៅអនាគត ។

សង្គមមួយដែលពោរពេញដោយមូលធនមនុស្ស ដែលជាពលរដ្ឋសកល មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមធ្វើការងារសង្គម បម្រើសង្គមជាតិ ចាំបាច់ណាស់បុគ្គលដែលមានទាំងជំនាញរឹង និងទន់ ។ ភាពចំបាច់ដែលមិនអាចខ្វះបាននោះគឺសម្បត្តិនៃសីលធម៌ ចរិយាធម៌ ដែលស្របនឹងពាក្យសុភាសិតខ្មែរថា" ដើយស្គកឱនដាក់គ្រាប់ " ។ ការចេះឱនលំទោន ស្គាល់ខុស ស្គាល់ត្រូវ មានសីលធម៌ប្រពៃនេះហើយជាសម្បត្តិដែលអ្នកដទៃគ្មាន ។ ការលើកពាក្យមួយថា " រឹងតែទន់ " ជាភាសាមួយដែលបង្ហាញពីជំហរច្បាស់លាស់ ហ្មត់ចត់ តែត្រូវចេះធ្វើបដិសណ្ឋារកិច្ច ប្រកបដោយភាពវិជ្ជមាន ។

ក្នុងបរិបថនេះ ទំនើបកម្មនៃបច្ចេកវិទ្យា ឧស្សាហកម្ម៤.០ ទាមទារឲ្យមនុស្សគ្រប់រូបត្រូវសិក្សា ឲ្យបានច្បាស់លាស់ នូវមូលដ្ឋានគ្រឹះនៃបច្ចេកវិទ្យា ហើយត្រូវផ្សារភ្ជាប់យ៉ាងជិតស្និតបំផុតទៅនឹងបញ្ហារបស់យើង ។ មួយផ្នែកនៃការធ្លាក់ចុះនៃសីលធម៌ និងក៏បានរួមចំណែកពីវិទ្យាសាស្ត្រដូចគ្នាដែរ ។ ដូច្នេះសាសនា សង្ឃចាំបាច់ត្រូវសិក្សាមូលដ្ឋាននៃបច្ចេកវិទ្យាឲ្យបានល្មមដែលអាចប្រើប្រាស់បាន ឬជំនួយការផ្សេងៗ ដើរតួជាកតាលីករដ៏ចាំបាច់ក្នុងការផ្សព្វផ្សាយអប់រំ សីលធម៌ ចរិយាធម៌សល់ពុទ្ធសាសនិកគ្រប់គ្នា ។

ទោះបីយើងដឹងថា សាសនាព្រះពុទ្ធ មិនមែនសម្រាប់តែការគោរពបូជា តែជាសាសនារបស់មនុស្សនិយមផង ជាសាសនាបែបទស្សនវិជ្ជាផង ក្នុងនោះក៏មានតួនាទីអប់រំសីលធម៌ ចរិយាធម៌សម្រាប់កុលបុត្រកុលធីតាខ្មែរផងដែរ ។ ទោះជាយ៉ាងក៏ដោយ ក្រៅពីគាំទ្រប្រធានដែលព្រះពុទ្ធសាសនាជាបន្ទុកនៃការអប់រំនោះ យើងក៏មិនបណ្ដោយឲ្យសាសនាបំពេញតួនាទីម្នាក់ឯង ធ្វើសកម្មភាពតែឯកឯងដែលភាគីដ៏ទៃមិនខ្វាយខ្វល់នោះទេ ទាំងសាមីខ្លួនផ្ទាល់ ទាំងគ្រួសារ សាលារៀន មិត្តភក្តិ អង្គការសង្គមស៊ីវិល ជាដើមត្រូវព្រួតដៃគ្នាសាមគ្គីគ្នាទើបអាចកែប្រែពន្លកល្អឲ្យផ្សុំបណ្ដុះពូជទុក បម្រើសង្គមនាពេលអនាគត ។

សីលធម៌ និងចរិយា ប្រៀបដូចជាពន្លឺដែលចាំងចែងមកពីក្នុងសម្រាប់ឲ្យអ្នកដទៃមើលនិងវាយតម្លៃ ដូច្នេះភាពចាំបាច់របស់មនុស្សគ្រប់រូប ត្រូវឈរលើសរសៃស្តម្ភ ចំណេះ ជំនាញ សីលធម៌ និងការចេះរស់នៅជាមួយគ្នាដោយស្មើភាព គោរពគ្នាទៅវិញទៅមក ដែលជាសម្បទាមិនអាចខ្វះបាននៃការកសាងមូលធនមនុស្សរបស់កម្ពុជា ។

# ឯកសារយោង


១. សម្ដេចសង្ឃរាជ ជួន ណាត *វចនានុក្រមខ្មែរភាគ១ ភាគ២* បោះពុម្ពឆ្នាំ ១៩៦៧
២.ភិក្ខុ ស៊ិន គង់ *ស្វែងយល់ពីព្រះពុទ្ធសាសនា* បោះពុម្ពឆ្នាំ ២០១១
៣.ឥន្ទ ឱមសាម៉េង *ប្រវត្តិទស្សនៈសាសនាសីលធម៌ នយោបាយ* បោះពុម្ពឆ្នាំ ២០០៥
៤.គេហទំព័រ ហ្វេសប៊ុក *ភិក្ខុ Ean Phearort*
៥គេហទំព័រ ហ្វេសបុក *ភិក្ខុ សំអ៊ាន សារុន*
៦.បណ្ឌិត ជា វណ្ណី *តម្លៃអប់រំនៃការបណ្ដុះធម្មចរិយា* បោះពុម្ពឆ្នាំ ២០២២
៧.ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ ភាគ១ភាគ២* បោះពុម្ពឆ្នាំ ១៩៧៣
៨.ក្រសួងអប់រំយុវជន និងកីឡា *អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២* បោះពុម្ពឆ្នាំ ២០១៣
៩.ក្រសួងអប់រំយុវជននិងកីឡា *សីលធម៌ពលរដ្ឋវិជ្ជា ថ្នាក់ទី១១* បោះពុម្ពឆ្នាំ ២០១៩
១០.ក្រសួងអប់រំ យុវជននិងកីឡា *សិក្សាសង្គមថ្នាក់ទី១០* បោះពុម្ពឆ្នាំ ២០១០
១១.ក្រសួងអប់រំយុវជននិងកីឡា *សីលធម៌ពលរដ្ឋវិជ្ជា ថ្នាក់ទី១២* បោះពុម្ពឆ្នាំ ២០១១
១២.អ្នកស្រី គី ធៀនឡាយ *កម្រងសុជីវធម៌* បោះពុម្ពឆ្នាំ ១៩៧០
១៣.ក្រុមនិស្សិតទី៦ (Rule) បង្រៀនដោយ គង់ ភូមីកា *សីលធម៌នៅក្នុងសង្គមខ្មែរ*
១៤. លោក ឈឹម ស៊ុមន៍ *គម្ពីរទេសជាតក* ឆ្នាំ ១៩៥៩
១៥. ព្រះអង្គ ឌួង *រឿង កាកី* ឆ្នាំ ១៨១៥
១៦. លោក ញ៉ុក ថែម *គម្ពីរបញ្ញាសជាតក* ឆ្នាំ ១៩៦៣
១៧.ក្រសួងធម្មការ និង សាសនា *ដែលផ្សព្វផ្សាយដោយផែកស្ថានទូតសហរដ្ឋអាមេរិកនៅកម្ពុជា*
១៨.https://km.wikipedia.org/wiki/
១៩.https://khmerbuddhism.wordpress.com/2012/01/20/
២០.https://vansary.blogspot.com/p/blog-page_68.html
២១. https://thmeythmey.com/